ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Apr-2015, 10:42
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥**

**ម៉ោង ០៨:០៣នាទី**

**សវនាការលើកទី២៦៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង
លោក រ៉ូជឺ ហ្វីលីព *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*
លោក សេង ប៊ុនឃាង
លោក ឌេល លីសាក់ *(Mr.Dale LYSAK)*
លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*
លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក រីឆាដ ឌុដម៉ាន (2-TCW-923) | អង់គ្លេស |
| លោកស្រី តាក សាន់ (2-TCCP-982) | ខ្មែរ |
| លោកស្រី អៀម យេន (2-TCCP-985) | ខ្មែរ |
| លោកស្រី ឆាយ ម៉ារីដែត (មន្ត្រី ធី.ភី.អូ) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក រីឆាដ ឌុដម៉ាន** (2-TCW-923)

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី.............................................ទំព័រ ៣

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី តាក សាន់** (2-TCCP-982)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី .............................................ទំព័រ ១៥

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី .............................................ទំព័រ ១៩

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី .............................................ទំព័រ ២៨

សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្ដើមពី.............................................ទំព័រ ៣៣

សួរដោយលោក គង់ សំអុន ផ្ដើមពី .............................................ទំព័រ ៣៨

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី អៀម យេន** (2-TCCP-985)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី .............................................ទំព័រ ៤៣

សួរដោយលោក ឡោ ជុនធី ផ្ដើមពី.............................................ទំព័រ ៤៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:០៣:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅព្រឹកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី រីឆាដ ឌុដម៉ាន តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក។ ហើយនៅរសៀលនេះ ចាប់ផ្តើមពីម៉ោងមួយរសៀល អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនានិងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប ដែលគាត់អះអាងថា គាត់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សូមភាគីនិងសាធារណជនជ្រាប។

ក្រឡាបញ្ជីសវនាការ លោកស្រី -- កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមានអវត្តមានភាគី និង បុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការព្រឹកនេះ។

[០៨:០៥:០៥]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃគឺលោក រីឆាដ ឌុដម៉ាន តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក។ តាមការបញ្ជាក់ពីផ្នែកបច្ចេកទេសសោតទស្សន៍ បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេសសម្រាប់ការស្តាប់សក្ខីកម្មនៅពេលនេះ បានរៀបចំរួចរាល់ហើយ។ រីឯសាក្សីក៏បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្តល់សក្ខីកម្មនេះដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មនៅរសៀលនេះ គឺមានពីររូបដែលមានរហស្សនាម 2-TCCP-982 និង 2-TCCP-985។ សូមអរគុណលោកប្រធាន។

[០៨:០៦:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ជា ស៊ីវហ័ង។ បាទ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះទទួលលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ដែលបញ្ជាក់ថាដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាលថែទាំសុខភាពជនជាប់ នួន ជា នៅអ.វ.ត.ក -- ជនជាប់ចោទនៅអ.វ.ត.កចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពលោក នួន ជា មានអាការៈឈឺចង្កេះរ៉ាំរ៉ៃ មិនអាចអង្គុយយូរបាន និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

[០៨:០៧:៥៦]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

សួស្តីលោក រីឆាដ ឌុដម៉ាន តើលោកបានរៀបចំខ្លួនរួចហើយ ឬនៅ?

**លោក រីឆាដ ឌុដម៉ាន៖**

បាទ ខ្ញុំរួចរាល់ហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឌុដម៉ាន ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះលោក។

សូមអញ្ជើញលោកស្រី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ លោកប្រធាន យើងខ្ញុំអត់មានសំណួរអីសម្រាប់សួរសាក្សីរូបនេះទៀតទេ លោកប្រធាន។

[០៨:០៩:១១]

**ប្រធានអង្គជំនុំ៖**

បាទ ដូច្នេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

សូមអញ្ជើញបាទ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ឌុដម៉ាន ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ឥឡូវនេះ គឺដល់វេនខ្ញុំសួរសំណួរមួយចំនួនទៅកាន់លោក។ ខ្ញុំមិនសួរវែងទេលោកសាក្សី។

**លោក រីឆាដ ឌុដម៉ាន៖**

**ឆ៖** ជម្រាបសួរ!

**ស៖** នៅពេលមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការនេះ លោកស្រី បេកឃ័រ បាននិយាយអំពីការរៀបចំខ្លួន ដើម្បីធ្វើដំណើរនៅខែធ្នូ ឆ្នាំ១៩៧៨ មកកាន់ប្រទេសកម្ពុជា។ នេះជាចម្លើយរបស់គាត់ ខ្ញុំ

នឹងដកស្រង់សៀវភៅរបស់គាត់ ជាភាសាអង់គ្លេស "នៅពេលដែលសង្គ្រាមរលត់ទៅ" ជាភាសាបារាំង មានន័យថា "ទឹកភ្នែកកម្ពុជា"។ ឃ្លាដែលខ្ញុំចង់នោះគឺនៅ ERN 00638654 ជាភាសាបារាំង, ជាភាសាអង់គ្លេស 00238115 គឺទំព័រ៩០២ជាភាសាអង់គ្លេស។ នេះជាអ្វីដែលលោកស្រី បេកឃ័រ បានសរសេរពាក់ព័ន្ធនឹងការរៀបចំខ្លួនសម្រាប់ការធ្វើដំណើរ។ "ឌុដម៉ាន និង ម៉ុរ បានដឹងពីស្ថានភាពអាក្រក់នៅកម្ពុជាមុននឹងពេលដែលយើងទៅដល់។ ខ្ញុំបានពិភាក្សាជាមួយអ្នកជំនាញក្រសួងការបរទេស ក្រសួងការពារជាតិ និង សេ.អ៊ី.អា នៅវ៉ាស៊ីនតោន។ នៅបាងកក និងនៅប៉េកាំង ខ្ញុំបានជួបអ្នកឯកទេសខាងនយោបាយ ហើយនិងអ្នកនយោបាយអាមេរិក បារាំង ចិន អូស្ត្រាលី។ គ្មានអ្នកណាបាននិយាយប្រាប់ខ្ញុំថា មានសង្គ្រាមទ្រង់ទ្រាយធំរវាងកម្ពុជានិងវៀតណាមទេ។ លើសពីហ្នឹងទៅទៀត ពួកគេយល់ថាវៀតណាមបានទៅដល់មេគង្គ ហើយបានឈប់នៅត្រង់ហ្នឹង។ ហើយបន្ទាប់មកទៀត គឺថាពួកគេគ្រោងនឹងមានការវាយប្រហារចូលមកខាងក្នុង។ អ្នកជំនាញការអាមេរិកម្នាក់ដែលជាមិត្តចាស់បានជួបខ្ញុំនៅបាងកក បាននិយាយប្រាប់ខ្ញុំថា ការព្រួយបារម្ភខ្ញុំហ្នឹងគឺគ្មានហេតុផលទេ"។ សូមបញ្ចប់ការដកស្រង់។ សំណួរទី១ របស់ខ្ញុំ ខ្ញុំចង់ដឹងថាតើលោក ឌុដម៉ាន លោកចាំទេ ថាលោកមានការប្រុងប្រយ័ត្នដូចដែលលោកស្រី បេកឃ័រ អ៊ីចឹងដែរ គឺថាលោកបានទទួលព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពការណ៍នៅកម្ពុជា មុននឹងរៀបចំការធ្វើដំណើររបស់លោកនៅឆ្នាំ១៩៧៨ មកកម្ពុជានោះ?

[០៩:១២:៣៨]

**ឆ៖** ខ្ញុំអត់ចាំថា ខ្ញុំបានធ្វើការរៀបចំអ្វីទេ ប៉ុន្តែខ្ញុំដឹងថា ខ្ញុំបាននិយាយទៅកាន់មនុស្សច្រើននាក់ណាស់ រួមទាំងកម្មាភិបាលមួយចំនួន ប៉ុន្តែខ្ញុំនឹកមិនឃើញថា ខ្ញុំបានធ្វើអ្វីពិតប្រាកដនោះទេ។

**ស៖** អ៊ីចឹងតើលោកចាំទេថា ដូចដែលលោកស្រី បេកឃ័រ បាននិយាយអ៊ីចឹងថា ដូចមិនមានអីការព្រួយបារម្ភពីការវាយប្រហារក្នុងពេលឆាប់ៗទេ? លោកមាននឹកឃើញពីចំណុចនេះទេ?

**ឆ៖** ខ្ញុំមិនចាំនូវអ្វីដែលខ្ញុំបានទទួលនោះទេ។

**ស៖** ពាក់ព័ន្ធទៅនឹងជម្លោះដែលកំពុងកើតឡើងរវាងកម្ពុជា និងវៀតណាម នៅក្នុងក្របខ័ណ្ឌនៃការរៀបចំខ្លួនសម្រាប់ការធ្វើដំណើរដដែលនេះ ហើយនិងក្នុងក្របខ័ណ្ឌនៃការធ្វើការរបស់លោកនៅក្នុងតំបន់ និងជាពិសេសពាក់ព័ន្ធនឹងវៀតណាមនោះ។ តើលោកមានបានធ្វើការស្រាវជ្រាវអំពីបញ្ហាព្រំដែនរវាងកម្ពុជានិងវៀតណាមទេ ជាពិសេសការពិភាក្សាគ្នាពាក់ព័ន្ធទៅនឹងខ្សែបន្ទាត់ប្រេវីយ៉េនោះ?

**ឆ៖** ខ្ញុំនឹកមិនឃើញថា ខ្ញុំបានធ្វើសិក្សាស្រាវជ្រាវអ្វីទេលោកស្រី។

**ស៖** ២ថ្ងៃកន្លងទៅនេះ ឬក៏ម្សិលមិញ ខ្ញុំភ្លេចហើយ លោកបាននិយាយថា លោកមានឱកាសក្នុងការស្តាប់ឡើងវិញនូវសម្តីរបស់ ប៉ុល ពត នៅពេលដែលលោកសម្ភាសជាមួយគាត់នៅឆ្នាំ១៩៧៨។ នៅក្នុងសម្រង់ដែលគេបានចាក់ស្តាប់នៅក្នុងសវនាការដោយមេធាវីការពារក្តីលោក នួន ជា ខ្ញុំគិតថា ប្រហែលជាម្សិលមិញ ប៉ុល ពត បាននិយាយអំពីឆន្ទះក្នុងការវាតទីនិយមរបស់វៀតណាម ហើយនិយាយថា នេះមិនមែនជាបញ្ហាព្រំដែនទេ។ អ៊ីចឹង តើលោកចាំកិច្ចសម្ភាសន៍នេះទេ? ហើយវាត្រូវគ្នានឹងអ្វីដែលលោកដឹងឮនៅសម័យនោះទេ? គឺថា វៀតណាមពិតជាមានឆន្ទៈក្នុងការវាតទីយកកម្ពុជាមែននោះ?

**ឆ៖** ខ្ញុំមិនចាំអំពីការសន្ទនានេះទេ។ ដូច្នេះ ខ្ញុំមិនដឹងថា តើត្រូវធ្វើការប្រៀបធៀបទៅនឹងអ្វីដែលខ្ញុំបានដឹងពេលនោះ ដោយរបៀបណាបានទេ។

**ស៖** តើលោកចាំទេថា នៅសម័យនោះយើងកំពុងតែស្ថិតនៅក្នុងសង្គ្រាមត្រជាក់? ហើយ ប៉ុល ពត គាត់មានបាននិយាយអំពីចំណុចហ្នឹងទេ គឺក៏គាត់និយាយថា មានការខិតជិតគ្នារវាងវៀតណាម និងសហភាពសូវៀត។ តើលោកមាននៅចងចាំអំពីហេតុការណ៍បែបហ្នឹងនៅសម័យនុ៎ងទេ?

[០៨:១៦:០៩]

**ឆ៖** ខ្ញុំនឹកមិនឃើញទេលោកស្រី។

**ស៖** នៅក្នុងរបាយការណ៍របស់លោក នៅខែមករា ឆ្នាំ១៩៧៩ គឺឯកសារ E3/3290 ERN 00419207 លោកបាននិយាយអំពីវត្តមានរបស់ចិននៅកម្ពុជា។ នេះជាអ្វីដែលលោកបានសរសេរ ខ្ញុំនឹងដកស្រង់ជាភាសាអង់គ្លេស ពីព្រោះខ្ញុំអត់មានការបកប្រែជាបារាំងទេ។ ចំពោះអ្នកបកប្រែ គឺមុនកថាខណ្ឌ *វែអាឌីវីដ* “មិនមានកន្លែងណាមួយដែលយើងធ្វើដំណើរហ្នឹង ឃើញអ្វីៗជា -- ឃើញមានកងទ័ពជាមួយនឹងអាវុធនោះទេ យើងឃើញមានតែជំនួយការចិននៅក្នុងប្រទេសដែលមានពីរនាក់ ដែលហោះហើរជាមួយខ្ញុំមកភ្នំពេញ។ ហើយមានឡានធំៗ ៥០បើកបរទៅកាន់ក្រុងកំពង់សោម”។ សូមបញ្ចប់ការដកស្រង់។

លោក ឌុដម៉ាន តើលោកមាននឹកឃើញអំពីផ្នែកនៃរបាយការណ៍នេះទេ? លោកមាននឹកឃើញទេថា ពិតជាបានឃើញហេតុការណ៍បែបហ្នឹងមែននោះនៅភ្នំពេញ?

**ឆ៖** ខ្ញុំអត់ចាំទេ។

**ស៖** លោកបាន -- (សូមទោស) គឺលោកស្រី បេកយ័រ បាននិយាយអំពីការស្លាប់របស់

ខាងវែល និងសម្មតិកម្មនានា ដែលបានធ្វើឡើងនៅសម័យនោះ។ នៅក្នុងរបាយការណ៍របស់លោក ដដែលគឺ E3/3290 នេះជាអ្វីដែលលោកសរសេរ។ ជាថ្មីម្តងទៀតគឺ ខ្ញុំនឹងនិយាយជាភាសាអង់គ្លេស លោកបាននិយាយអំពីសម្តីរបស់ ជួន ប្រាសិទ្ធ។ "ប្រាសិទ្ធ បានរៀបរាប់ការបាញ់ប្រហារនេះថា ជាអំពើនយោបាយដើម្បីធ្វើឲ្យខូចកេរ្តិ៍ឈ្មោះនិងបង្ហាញឲ្យឃើញថា យើងមិនអាចការពារមិត្តរបស់យើងបាន។ គាត់បាននិយាយថា ភេរវករដឹងថា ការចូលមករបស់អ្នកកាសែតបស្ចិមប្រទេសទាំងបីគឺជារឿងសំខាន់បានន័យថាកិត្តិយសកម្ពុជានៅ -- កិត្តិយសកម្ពុជាគឺថានឹងធ្លាក់ចុះថយ បើសិនណាជាវានឹង -- ប៉ុន្មានថ្ងៃក្រោយមកបានអះអាងថា វាជាអំពើរបស់វៀតណាម"។ សូមបញ្ចប់ការដកស្រង់។

សំណួរដដែលលោក ឌុដម៉ាន តើលោកចាំអំពីផ្នែកនៃរបាយការណ៍នេះទេ? តើលោកចាំទេថា ជួន ប្រាសិទ្ធ ពិតជាបាននិយាយតាំងពីថ្ងៃដំបូងអំពីសម្មតិកម្មនៃការវាយប្រហាររបស់វៀតណាមនោះ?

[០៨:១៩:៤៨]

**ឆ៖** ខ្ញុំអត់យល់សំណួរលោកស្រីទេ។

**ស៖** ខ្ញុំសួរលោកថា តើលោកមានចាំរបាយការណ៍ដែលលោកសរសេរផ្នែកហ្នឹងទេ? ហើយប្រសិនបើចាំនោះ ថាតើ ជួន ប្រាសិទ្ធ ពិតជាបាននិយាយអំពីសម្មតិកម្មពាក់ព័ន្ធទៅនឹងការវាយប្រហាររបស់វៀតណាម គឺការវាយប្រហារជាលក្ខណៈភេរវកម្ម ដែលតាំងពីថ្ងៃដំបូងនៃការសម្លាប់ហ្នឹងទេ?

**ឆ៖** ខ្ញុំពិតជាមិនដឹងទេ។ ខ្ញុំកំពុងតែគិតទៅដល់ពេលហ្នឹង ថាអ្វីដែលខ្ញុំបានសរសេរនៅពេលនោះ គឺជាអ្វីដែលខ្ញុំបានដឹងនៅពេលនោះ ឬក៏ ប៉ុន្តែខ្ញុំនឹកមិនឃើញអ្វីលើសពីការសរសេរហ្នឹងទេ។

**ស៖** នៅក្នុងរបាយការណ៍ដដែលនេះ លោកក៏បានលើកឡើងផងដែរអំពីសម្តីរបស់ អៀង សារី គឺនៅ ERN ដដែល 00419212 ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ "អៀង សារី បាននិយាយថា ការទស្សនកិច្ចហ្នឹងគឺថា បង្ហាញទៅជាពិភពលោកអំពីស្ថានភាពនៅហ្នឹងដែលថា ឧបទ្ទវហេតុភេរវកម្មហ្នឹងគឺថា បានជះដុំពកខ្មៅមកលើប្រទេសយើង។ រដ្ឋាភិបាលកម្ពុជាបានអះអាងថា វាជាអំពើភេរវកម្មរបស់វៀតណាមដែលជាខ្មាំងនៅក្នុងសង្គ្រាមនាពេលបច្ចុប្បន្ន ហើយដែលបង្កបញ្ហាក្នុងពេលទស្សនកិច្ចនេះ" សូមបញ្ចប់ការដកស្រង់។ សំណួរដដែល លោក ឌុដម៉ាន តើលោកមាននឹកឃើញឡើងវិញទេ តើលោក--?

**ឆ៖** ដែលមិនមែនអ៊ីចឹងទេ នឹកៗមិនឃើញទេ។

[០៨:២២:០១]

**ស៖** សម្រង់ចុងក្រោយ ពាក់ព័ន្ធទៅនឹងរបាយការណ៍របស់លោកនៅឆ្នាំ១៩៧៨ លោកបាន លើកឡើងអំពីសម្មតិកម្មមួយចំនួន។ ហើយនៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលមានទស្សនៈផ្សេងៗពាក់ព័ន្ធនឹងការសម្លាប់នេះ ហើយមានការទាយស្មាន។ លោកចាំថា មានពាក្យចចាមអារ៉ាមជាច្រើនពាក់ព័ន្ធទៅនឹងការធ្វើឃាត ខាដវែល។ នេះជាចម្លើយរបស់លោកនៅ ចុងក្រោយរបាយការណ៍របស់លោក ពាក់ព័ន្ធទៅនឹងសម្មតិកម្មនៃការវាយប្រហារដែលធ្វើឡើងដោយរដ្ឋាភិបាលខ្មែរក្រហម។ លោកបានសរសេរដូចតទៅ៖ “ទីបញ្ចប់មានលទ្ធភាពណាដែលរដ្ឋាភិបាលអាចធានាចំពោះការវាយប្រហារនេះបានទេ។ ខាដវែល គឺថា មានបំណងប្រឆាំងទៅនឹងកម្ពុជាដើម្បីបង្ហាញថារដ្ឋាភិបាលកម្ពុជាចង់ការពារនូវអ្វីដែលខ្លួនមានការភ័យខ្លាច។ នេះហាក់បីដូចជាវាមិនអាចដោះស្រាយបញ្ហាបានទេ រដ្ឋាភិបាលកម្ពុជាព្យាយាមទប់ស្កាត់កុំឱ្យមានបញ្ហានេះកើតឡើង។ បើសិនណាជាមានហេតុផលណាមួយពាក់ព័ន្ធទៅនឹងការកាប់សម្លាប់នេះគឺថា គេអាចពួនលបស្ទាក់វាយប្រហារយើងផងមិនត្រឹមតែវាយប្រហារអ្នកទាំងនេះទេ។ តាមការសន្និទានមកអ៊ីចឹង ព្រោះ ខាដវែល រយៈពេលពីរបីឆ្នាំអំពីការស្លាប់របស់គាត់នេះគឺថា យើងមានការ គាត់មានសន្តានចិត្តចំពោះបដិវត្តន៍កម្ពុជា”។ សូមបញ្ចប់ការដកស្រង់។ សំណួរទី១ ពាក់ព័ន្ធនឹងចំណុចនេះ តើលោកចាំទេ ថាលោកបានធ្វើការសន្និដ្ឋានបែបហ្នឹងមែននៅសម័យនោះ? អ៊ីចឹងសុំសួរប៉ុណ្ណេះសិន តើលោកចាំអំពីសេចក្ដីសន្និដ្ឋានរបស់លោកហ្នឹងទេ? គឺជាអ្វីដែលលោកគិតឃើញមែនទេ នៅឆ្នាំ១៩៧៨ ថាការវាយប្រហារហ្នឹង គឺវាអត់មានផលប្រយោជន៍អីសម្រាប់រដ្ឋាភិបាលកម្ពុជាទេ។

**ឆ៖** ខ្ញុំបានអាននូវថ្ងៃនេះ ប៉ុន្តែអ្វីដែលខ្ញុំបានសរសេរនៅពេលនោះ គឺខ្ញុំមិនមាន ខ្ញុំមិនចាំថា មានអ្វីដែលនាំឱ្យខ្ញុំសរសេរអំពីបញ្ហានេះទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណចំពោះការអត់ធ្មត់របស់លោកក្នុងការឆ្លើយទៅហ្នឹងសំណួររបស់ខ្ញុំ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[០៨:២៥:០៧]

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីថៅក្រមមានសំណួរទេ?

បាទ ហើយសវនាការព្រឹកនេះដល់ពេលសម្រាកហើយដោយសារការធ្វើសវនាការនៅព្រឹកនេះ

បានចប់មុនពេលកំណត់។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីនៅព្រឹកនេះត្រឹមនេះ ហើយសវនាការលើកបន្តធ្វើនៅរសៀលថ្ងៃនេះដែលនឹងចាប់ផ្ដើមពីម៉ោងមួយរសៀល។ ហើយសវនាការនៅរសៀលថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូប ដែលបានអះអាងថាខ្លួនបានទទួលរងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ១៧ មេសា ៧៥ ដល់ ០៦ មករា ៧៩។ សូមភាគីរួមទាំងបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយអង្គជំនុំជម្រះសូមអរគុណចំពោះលោក រីឆាដ ឌុដម៉ាន សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ដំណើរការស្ដាប់សក្ខីកកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅពេលនេះបានដល់ទីបញ្ចប់ហើយ។ លោក រីឆាដ ឌុដម៉ាន លោកអាចសម្រាកបានហើយ ហើយសូមជូនពរលោក រីឆាដ ឌុដម៉ាន សូមមានសុខភាពល្អ ជួបតែសំណាងល្អ។ ហើយអង្គជំនុំជម្រះក៏សូមអរគុណផងដែរចំពោះលោកមេធាវី ចេសិន បារ៉េត និងលោក ថូដ ឡូវែល ជាបុគ្គលិកជំនួយការមេធាវីដែលបានចូលរួមជួយជ្រោមជ្រែង អង្គជំនុំជម្រះក្នុងអំឡុងពេលដែលលោក រីឆាដ ឌុដម៉ាន ផ្ដល់សក្ខីកម្មពាថ្ងៃ រយៈពេល៦ម៉ោងកន្លងមកនេះ ឥឡូវនេះបានដល់ទីបញ្ចប់ហើយ លោកមេធាវី ចេសិន បារ៉េត និងលោក ថូដ ឡូវែល អាចសម្រាកបានហើយ។

**លោក រីឆាដ ឌុដម៉ាន៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជម្រាបលាលោក រីឆាដ ឌុដម៉ាន។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៨:២៧:១១]

**លោក ឌេល លីសាក់៖**

មុនពេលឈប់សម្រាកលោកប្រធាន កាលពីម្សិលមិញនោះ ខ្ញុំបានលើកឡើងអំពីការចងចាំរបស់ខ្ញុំ ខ្ញុំដឹងថាយើងបានពិភាក្សាពីម្សិលមិញហើយ ដែលបានរៀបដោយក្រុម នួន ជា គឺការតាំងសំណួរ ឬការជំទាស់តវ៉ា ចំពោះការប្រើប្រាស់ព្យសនកម្មរបស់ជនរងគ្រោះពាក់ព័ន្ធទៅនឹងសំណុំរឿងនេះ។ ខ្ញុំបានពិនិត្យមើលប្រតិចារឹក ហើយខ្ញុំបានរកឃើញអ្វីដែលយើងបាន -- នៅថ្ងៃទី២០ ខែឧសភា ២០១៣ នេះគឺរយៈពេល១សប្ដាហ៍មុននឹងការតាំងសំណួរអំពីព្យសនកម្មត្រូវបានចាប់ផ្ដើម ហើយមានការជំទាស់តវ៉ា

នៅដំណាក់កាលចុងក្រោយនៃថ្ងៃនោះរវាងមេធាវី ហើយនិងព្រះរាជអាជ្ញាក៏អនុញ្ញាតឲ្យបានសួរៗអំពីព្យសនកម្មនេះផងដែរ។ គឺនៅត្រង់ទំព័រ១០០ ទៅ១១១ នៅថ្ងៃទី២០ ខែឧសភា គឺ E1/133.1 ដែល -- គឺឯកសារ 1/193.1 ដែលសម្អាងទៅលើអង្គហេតុរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ដើមបណ្ដឹងរដ្ឋប្បវេណីនេះបានសង្កត់ធ្ងន់ថា សូមដកស្រង់ដាក់ថា៖ “ដើមបណ្ដឹងរដ្ឋប្បវេណីគួរត្រូវបានអនុញ្ញាតឲ្យសួរនូវបញ្ហាពាក់ព័ន្ធទាំងអស់ ដែលថាភស្តុតាងពាក់ព័ន្ធទៅនឹងការឈឺចាប់ ហើយនិងឧក្រិដ្ឋកម្មនេះគឺឧក្រិដ្ឋកម្មទាំងនេះមានការជាប់ពាក់ព័ន្ធយ៉ាងខ្លាំង ហើយគាត់ក៏និយាយថាតើដើមបណ្ដឹងរដ្ឋប្បវេណីក៏ជាជនរងគ្រោះ ហើយជាបេះដូងរបស់សវនាការនេះ។ ដឹងថាមេធាវីការពារក្ដីក៏ត្រូវគួរផ្ដល់ឱកាសឲ្យធ្វើការជំទាស់តវ៉ាទៅលើភស្តុតាងទាំងនេះផងដែរ”។ គាត់បាននិយាយយ៉ាងដូច្នេះ ខ្ញុំសូមដកស្រង់៖ “មេធាវីការពារក្ដីត្រូវឲ្យមានសិទ្ធិសួរតទល់ពេញលេញ” បញ្ចប់ការដកស្រង់។ ហើយក៏ដឹងថាតួនាទីរបស់អង្គជំនុំជម្រះដើម្បីស្វែងរកការពិត មានន័យថាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានសួរអំពីព្យសន-កម្មដែលកើតឡើងទៅលើជនរងគ្រោះដូចដើមបណ្ដឹងរដ្ឋប្បវេណីដទៃទៀតដែរ។

[០៩:២៩:៤៧]

នៅក្នុងការឆ្លើយតបទៅនឹងមេធាវី កូប៉េ ខ្ញុំសូមដកស្រង់៖ “លោកប្រធាន ខ្ញុំមិនគិតថា ខ្ញុំបាននិយាយយ៉ាងដូច្នេះទេនៅចំពោះមុខតុលាការ ប៉ុន្តែខ្ញុំយល់ស្របជាមួយនឹងសំណើសុំទាំង១០របស់សហព្រះរាជអាជ្ញា។ ដូច្នេះ យើងយល់ស្របទាំងស្រុងជាមួយសំណើសុំរបស់សហព្រះរាជអាជ្ញា។”។ ហើយក្រោយមក ក្រុមមេធាវីការពារក្ដី ខៀវ សំផន –*មីស្ទ័រ* វែកគែន– ក៏យល់ស្របជាមួយជំហររបស់យើងខ្ញុំផងដែរ ខ្ញុំសូមដកស្រង់សម្ដីគាត់ “ការនាំមនុស្សមកទីនេះ ឲ្យមកនិយាយចំពោះមុខតុលាការ និយាយតែអំពីព្យសនកម្មដែលគេទទួលរងគ្រោះ។ បើមិនមានពន្យល់ហេតុផលដែលនាំឲ្យមានព្យសនកម្មនេះ គឺសម្រាប់យើងខ្ញុំ ខ្ញុំថាវាមិនមានហេតុអ្វីនោះទេ។ វាពិបាកនៅក្នុងការញែកគ្នាឲ្យបានច្បាស់ អំពីអង្គហេតុដែលនាំឲ្យមានការកើតនូវព្យសនកម្មនេះ និងព្យសនកម្មខ្លួនវាផ្ទាល់។ ដូច្នេះ សម្រាប់ខ្ញុំគិតថា វាធម្មតាទេ ប្រសិនណាអ្នកទាំងនេះមកសប្ដាហ៍ក្រោយ ហើយសួរពាក់ព័ន្ធទៅនឹងព្យសនកម្ម។ ហើយរួចហើយទៅជាបែរបង្វែរចូលទៅអង្គហេតុផ្សេងទៅវិញ។ យើងត្រូវតែរៀបចំចាត់ចែងដោះស្រាយបញ្ហានេះតាមដែលអាចធ្វើទៅបានដើម្បីសាកសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះ”។

នៅថ្ងៃបន្ទាប់ គឺនៅថ្ងៃទី២១ ខែឧសភា នៅចុងបញ្ចប់នៅថ្ងៃនោះ គឺឯកសារប្រតិចារឹកសម្រាប់ ២១ ខែឧសភា គឺ E1/194.1 នៅត្រង់ទំព័រ១១៩ អង្គជំនុំជម្រះ ក៏បានសម្រេចទៅលើចំណុចនេះ ហើយ

ខ្ញុំសូមដកស្រង់ គឺថា "មានៗការយល់ស្របគ្នា ក្នុងចំណោមភាគីទាំងអស់។ ហើយអង្គជំនុំជម្រះសម្រេចថា ភាគីទាំងអស់ហ្នឹងអាចតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណីទៅលើអង្គហេតុពាក់ព័ន្ធដោយយោងទៅលើកម្មវត្ថុ ហើយនិងវិសាលភាពនៃរឿងក្ដីនេះ។ នៅពេលដែលយើងសាកសួរ អំពីកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធទៅនឹងផលប៉ះពាល់លើជនរងគ្រោះ ម្នាក់ៗដឹងថា ពួកគេក៏បានអាចមានសិទ្ធិសួរដែរ មិនមែនសួរតែត្រឹមព្យសនកម្មទេ សួរទៅលើអង្គហេតុពាក់ព័ន្ធផងដែរ។ អ៊ីចឹងហើយ បានជាភាគីទាំងអស់តាំងសំណួរបែបនេះ។ ហើយហេតុដូច្នេះ បានជាអង្គជំនុំជម្រះបានលើកចំណុចនេះឡើងនៅក្នុងសាលក្រម។"

ជាឱកាសមួយល្អសម្រាប់ខ្ញុំ ដែលថាការជំទាស់តវ៉ាដែលបានលើកឡើងកាលពីម្សិលមិញ ជូនអង្គជំនុំជម្រះនេះ គឺថាមិនមែនជាឧបទ្ទវហេតុតែមួយ ដែលមាននៅក្នុងបណ្ដឹងសាទុក្ខរបស់ក្រុម នួន ជា នោះទេ។ ដូច្នេះ ខ្ញុំអាចស្នើសុំថា ក្រុម នួន ជា គឺចង់ដាក់សារណាពាក់ព័ន្ធទៅនឹង -- បានដាក់សំណើសុំ ប៉ុន្ដែមិនភ្ជាប់ទៅនឹងសារណានៃបណ្ដឹងសាទុក្ខនោះទេ។ ដែលការបញ្ហានេះ គឺទុកឲ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេច។ ខ្ញុំយល់ឃើញថា វាជាកំហុសឆ្គងមួយ ទោះជាករណីក៏ដោយ គឺថាត្រូវតែមានភាពច្បាស់លាស់ថា នៅសវនាការពីកន្លងទៅ តុលាការនៅចំពោះមុខយើង បានប្រកាសហើយថា ដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវសាកសួរ ពាក់ព័ន្ធទៅនឹងអង្គហេតុនានា ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះតែម្ដង។ សូមអរគុណលោកប្រធាន។

[០៨:៣៣:២៥]

**ប្រធានអង្គជំនុំ៖**

វ៉ិចទ័រ កូប៉េ កុំអាល់ទាន់! សូមអញ្ជើញលោកចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

ដូចជាមិនការបកប្រែទេ។ អញ្ជើញលោកស្រីចៅក្រមចាប់ផ្ដើមសាឡើងវិញ សាជាថ្មីឡើងវិញ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគ្រាន់តែសុំបន្ថែម ថាមានសេចក្ដីសម្រេច E267/3 ចុះថ្ងៃទី០២ ឧសភា ២០១៣ ពាក់ព័ន្ធទៅនឹងបញ្ហាថា ដែលយើងនៅមានចំពោះមុខ។ ខ្ញុំគិតថា វាជាមូលដ្ឋានសម្រាប់ការពិភាក្សានៅថ្ងៃទៅមុខ

សម្រាប់ថ្ងៃមុខផង។ នេះគឺជាការលើកឡើងរបស់ក្រុមមេធាវីការពារក្តី នួន ជា នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន។ ហើយជាពិសេស នៅត្រង់ទំព័រ៩ នៃសេចក្តីសម្រេច គឺពាក់ -- វាបានលើកឡើងនូវបញ្ហាពាក់ព័ន្ធទៅនឹងបញ្ហាដែលបាន ដែលក្រុម នួន ជា បានលើកឡើងកាលពីម្សិលមិញ ដែលបញ្ជាក់ថាការសួរតទល់នឹងត្រូវបានអនុញ្ញាត។ ហើយនៅត្រង់កថាខណ្ឌ២១ និយាយជាទូទៅតែម្តង ថាតើអង្គជំនុំជម្រះសាលាដំបូងដោះស្រាយជាមួយនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងផលប៉ះពាល់ផងនោះដោយរបៀបណា? ហេតុផលដែលខ្ញុំមិនបានលើកកាលពីម្សិលមិញ គឺថាដោយសារថា វាបាននិយាយនៅក្នុងបណ្តឹងសាទុក្ខទៅហើយ ហើយខ្ញុំព្យាយាមគ្រាន់តែលើកឡើង អាចថា ក្រែងលោអាចដកស្រង់បញ្ហាណាមួយខុសចេញពីសេចក្តីសម្រេចណាមួយ។ ដូច្នេះ ដើម្បីបន្ថែមទៅនឹងការជំទាស់តវ៉ា ខ្ញុំសូមបង្ហាញចំណុចនេះឲ្យបានយល់ទាំងអស់គ្នា។ សូមអរគុណ។

[០៨:៣៥:៥៤]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកស្រីចៅក្រម ហ្វេនស៍។ ហើយដូចដែលតំណាងសហព្រះរាជអាជ្ញារងទើបតែលើកឡើងថា ជាការពិតហើយពីម្សិលមិញ ខ្ញុំបានពិនិត្យមើលបណ្តឹងសាទុក្ខរបស់យើងខ្ញុំ ហើយខ្ញុំក៏បានពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងបញ្ហានេះផងដែរ។ ហើយសម្រាប់ខ្ញុំគឺថាយើងមានការបកស្រាយខុសគ្នាទាំងស្រុងទៅនឹងសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងបញ្ហានេះ។ សម្រាប់យើងខ្ញុំវាច្បាស់ហើយភាពខុសគ្នារវាងសក្ខីកម្ម ដែលសាក្សីបានផ្តល់ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់នោះ នៅពេលដែលពួកគាត់មកទីនេះ ហើយផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងអង្គហេតុនានា។ ហើយនិងផលប៉ះពាល់មកលើដើមបណ្តឹងរដ្ឋប្បវេណី ដូចជា ជាក់ស្តែង គឺថាដើមបណ្តឹងរដ្ឋប្បវេណីនិយាយអំពីការឈឺចាប់ ដែលខ្លួន -- និយាយទៅវាពាក់ព័ន្ធទៅនឹងអង្គហេតុដែលជាប់ពាក់ព័ន្ធនេះ។ ខ្ញុំយល់ថា ជាសំខាន់ហ្នឹង គឺថាមិនមានភស្តុតាងណាមួយ ភស្តុតាងដែលមិនត្រូវយកមកប្រើប្រាស់ប្រឆាំងនឹងជនជាប់ចោទភ្លាមៗនៅក្នុងសាលក្រម គេមិនត្រូវយកមកប្រើប្រាស់នោះទេ។ នេះយើងយល់របៀបនេះឯង។ អ៊ីចឹងឯង ខ្ញុំនៅតែយល់ថាយ៉ាងដូច្នេះ។

នៅក្នុងបណ្តឹងសាទុក្ខរបស់យើងខ្ញុំ យើងខ្ញុំបានដកស្រង់នូវសេចក្តីសម្រេចរបស់សាលាដំបូង។ អង្គហេតុតែមួយដែលថា រយៈពេល១០នាទី ដែលបានផ្តល់មកឲ្យយើងខ្ញុំ ឲ្យសួរសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី អំពីផលប៉ះពាល់នេះ គឺជាធាតុមួយដែលបញ្ជាក់អំពីឃើញថា ចំពោះការបកស្រាយ

របស់យើងខ្ញុំ និងការយល់ឃើញរបស់យើងខ្ញុំ។ ហើយកាលពីម្សិលមិញលោកបានសួរ អនុញ្ញាតឱ្យមេធាវីការពារក្ដីបន្ទរការសាកសួរនៅពេលដែល នួន ជា គាត់ឈឺ មិនមានវត្តមាន យើងតែងតែបំពេញកិច្ច ពាក់ព័ន្ធទៅនឹងការឈឺចាប់នេះ ចង់ -- សក្ខីកម្មពាក់ព័ន្ធទៅនឹងការឈឺចាប់ ហើយនិងសក្ខីកម្មពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងទៀត។ នៅពេលនោះក្នុងការឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញារងអន្តរជាតិ លីសាក់ យើងបានយល់ស្របទាំងស្រុងជាមួយ ឃើត វេយ៍ន័រ ដោយសារតែថា យើងត្រូវតែទទួលបានឱកាសស្មើគ្នា បទដ្ឋានអនុវត្តជាក់ស្ដែងគឺថាលោកមាននៅពេល១០នាទី ដើម្បីសួរសំណួរបន្តទៅទៀតបន្ថែម។

[០៨:៣៨:៣៩]

យើងខ្ញុំគួរតែទទួលបាននូវការរំឭកឱ្យដឹងនូវភាពខុសគ្នារវាងដើមបណ្ដឹងរដ្ឋប្បវេណី សួរទៅនឹងព្យសនកម្ម ហើយក្រោយមកសួរផលប៉ះពាល់ ឬក៏ជាជាងការដែលគ្រាន់តែកំណត់ពេលមកទីនេះ កន្លះម៉ោង ឬក៏មួយម៉ោងនោះ។ ទោះជាក្នុងករណីនេះក៏ដោយ នៅក្នុងបណ្ដឹងសាទុក្ខរបស់យើងខ្ញុំ យើងខ្ញុំបង្ហាញថា យើងមានការបកស្រាយផ្សេងគ្នា។ តើច្បាប់និយាយថាម៉េចទៅលើបញ្ហានេះ? យើងជាមេធាវីការពារក្ដី យើងសម្រេចចិត្តបែបនេះឯង ហើយយើងឃើញមានបញ្ហាខុសឆ្គង។ ដូច្នេះ យើងរង់ចាំមើលថាទុកឱ្យតុលាការកំពូលសម្រេច ហើយយើងនឹងទទួលយកនៅពេលមានសេចក្ដីសម្រេច។ ប៉ុន្តែសម្រាប់យើងខ្ញុំវាមានភាពមិនច្បាស់លាស់ថា តើច្បាប់បកស្រាយថាដូចម្ដេច? ហើយនៅពេលនេះលោក បើលោកនិយាយថា នេះជាការបកស្រាយសេចក្ដីសម្រេចនេះ គឺថាយើងនឹងមានជម្រើសរបស់យើង គឺថាយើងខ្ញុំស្នើសុំឱ្យមានពេលវេលាស្មើគ្នា ដើម្បីសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីដែលចូលខ្លួនជាបន្តបន្ទាប់នេះ បន្តបន្ទាប់មកនេះ។ នេះជាការយល់ឃើញ និងការបកស្រាយរបស់យើងខ្ញុំ។

ហេតុដូច្នេះឯង លោកនឹងឃើញនៅក្នុងបណ្ដឹងសាទុក្ខរបស់យើងខ្ញុំហើយ កំណត់សម្គាល់ចុងក្រោយ។ អំពីកំណត់សម្គាល់របស់សហព្រះរាជអាជ្ញា និងយើងផ្ដល់ហេតុផលហេតុអ្វីបានជាយើងបានដកសម្រង់ចេញពីសារណាបណ្ដឹងសាទុក្ខនេះ ដើម្បីជាមូលហេតុនៃការធ្វើទៅឱ្យសវនាការប្រព្រឹត្តទៅឱ្យឆាប់រហ័ស។ យើងមានការឆ្លើយតបបានយ៉ាងពេញ ជាពិសេសពាក់ព័ន្ធនឹងអង្គហេតុដែលផ្ដល់ឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងផលប៉ះពាល់ ហើយនិងព្យសនកម្មមកលើខ្លួន។

ដូច្នេះជាថ្មីម្ដងទៀត សម្រាប់ពេលនេះគឺថា ភាគីដទៃហាក់បីដូចជាយល់ច្បាស់ហើយ តែសម្រាប់យើងខ្ញុំ ខ្ញុំនៅតែយល់មិនទាន់ច្បាស់នៅឡើយទេ។

[០៨:៤០:៤០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញក្រុមមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយដោយខ្លីទេ គឺថាដកស្រង់ ការដកស្រង់នៃអនុស្សរណៈរបស់ចៅក្រម។ ឯកសារ E236/236 -- /35/32 អ្វីដែលយើងយល់ពីម្សិលមិញនេះគឺវាងនៃការមកផ្តល់សក្ខីកម្មពីរប្រភេទដែលរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមកផ្តល់សក្ខីកម្មនៅទីនេះ គឺថាហើយនិង គឺថាមានមួយមកផ្តល់សក្ខីកម្មលើអង្គហេតុ មួយមកផ្តល់សក្ខីកម្មលើព្យសនកម្ម។ អ៊ីចឹងៗត្រូវដើមបណ្តឹងរដ្ឋប្បវេណីមួយគឺ TC-13 គោលបំណងគឺថាចង់និយាយអំពីការផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីនូវលទ្ធភាពក្នុងការផ្តល់ភស្តុតាង ហើយនិងការធ្វើសំណាងជារួម ហើយនិងតាមផ្លូវចិត្ត នេះគឺជាវិធានផ្ទៃក្នុង២៣(១)(២)។ កាលនោះពេលខ្ញុំយល់ទាក់ទងនឹងការសំណាងនេះ គឺថាកាលណោះគឺថាមានការផ្តន្ទាទោស ហើយបន្ទាប់មកទៀតគឺសុំសំណាង ទាល់តែមានទោសហើយបានសុំសំណាងបាន។ អ៊ីចឹងហើយបាននៅក្នុងសំណុំរឿង០០២/០១ នេះយើងមិនបានសួរទៅដើមបណ្តឹងរដ្ឋប្បវេណីច្រើនទេ នៅពេលដែលពួកគាត់មកថ្លែងទុក្ខសោក ព្រោះថាយើងដឹងថា មានការបែងចែករវាងសវនាការដែលគាត់មកផ្តល់សក្ខីកម្មនៅក្នុងឋានៈជាអ្នកផ្តល់សក្ខីកម្មលើអង្គហេតុ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីដែលមកផ្តល់សក្ខីកម្មៗ គឺថាដើម្បីសុំសំណាង។

[០៨:៤២:៥៣]

ដូច្នេះអង្កាល់ណោះយើងច្បាស់ណាស់ គឺថាមិនយើងមិនអាចបែងចែកអង្គហេតុឲ្យដាច់តែម្តងអំពីការឈឺចាប់នោះទេ ព្រោះថាដើមបណ្តឹងរដ្ឋប្បវេណីមកគាត់និយាយអំពីការឈឺចាប់។ ក៏ប៉ុន្តែវាមានអង្គហេតុដែលត្រូវតែពិភាក្សានៅចំពោះមុខអង្គជំនុំជម្រះ ដែលអាចចេញជាការសុំសំណាង ព្រោះថាមានការសុំសំណាង។ នៅក្នុងករណីនេះគឺ ការបំភ្លឺរបស់យើងនៅថ្ងៃនេះគឺថា នៅកថាខណ្ឌទី៣០នៃសារណាបណ្តឹងសាទុក្ខរបស់យើងគឺថា យើងឃើញថាមានការប្រើប្រាស់ជាច្រើននូវចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលកាលណោះគាត់មកហ្នឹង មកសុំតែសំណាងសមូហភាព ហើយនិងផ្លូវចិត្តនោះទេ ហើយទៅប្រើប្រាស់ចម្លើយរបស់នេះមកដាក់បន្ទុកទៅវិញ។ ដូច្នេះយើងតែងតែព្យាយាមឲ្យច្បាស់លាស់ក្នុងចិត្ត គឺថាសំណួរដែលយើងសួរទៅ យើងសួរឲ្យច្បាស់ បើសិនជាថាមានភស្តុតាងថ្មីនោះ ភស្តុតាងថ្មី

ចំពោះយើងនោះមិនមែនជារឿងងាយស្រួលនោះទេ ព្រោះថាមាន ព្រោះថាពេលខ្លះអ្វីចម្លើយរបស់គាត់នៅក្នុងឯកសារនោះមានតិចបំផុត ប៉ុន្តែដល់ពេលដែលគាត់មកផ្តល់សក្ខីកម្មនោះ បានយើងដឹងថាពេលខ្លះមានភស្តុតាងថ្មីដែលលេចឡើង ហើយតម្រូវឱ្យយើងមានពេលវេលាច្រើនដើម្បីសួរទៅពួកគាត់។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៨:៤៤:៤៥]

**លោក ឌេល លីសាក់៖**

ខ្ញុំនឹងលើកឡើងសង្ខេបទេ អ្វីដែលយើងខ្ញុំបានឮគឺ ដែលនិយាយអំពី គឺយើងអានប្រតិចារឹកចុះថ្ងៃទី២០ ឧសភា ២០១៣នេះគឺមិនមានភាពមិនច្បាស់លាស់ទេ មិនមានចំណុចកន្លែងណាមួយសម្រាប់ឱ្យលោក កូប៉េ ដែលថាពួកគាត់មិនបានដឹងអំពីគោលបំណងដែល -- នៃផលប៉ះពាល់ទៅលើដើមបណ្តឹងរដ្ឋប្បវេណីទេ។ មិនអាចមិនច្បាស់អ៊ីចឹងបានទេ ត្រូវតែច្បាស់។ ដើមបណ្តឹងរដ្ឋប្បវេណី គឺនឹងត្រូវសាកសួរអំពីព័ត៌មានពាក់ព័ន្ធទៅនឹងអង្គហេតុនានា។ នេះគឺជាបញ្ហាហ្នឹង អានចំណុចទាំង១០ ដែលលើកឡើងដោយលោក វេយ៍ន័រ អានអ្វីដែលលោកមេធាវីការពារក្តីដទៃទៀតលើកឡើង គឺបញ្ហាហើយ ដែលពួកគេបានទៅបែរទៅជាប្រឌិតឡើងទៅវិញ ក្រោយពីការចេញសាលក្រម។ ខ្ញុំសូមលើកឡើងជាសាមញ្ញយ៉ាងដូច្នេះ។

**ប្រធានអង្គជំនុំ៖**

បាទ រឿងនេះគឺចប់ត្រឹមនេះចុះ ព្រោះពីរពេលហើយ។ ម្សិលមិញក៏និយាយ ហើយថ្ងៃណេះនិយាយដោយមិនបានគ្រោងទុកជាមុនទៀតផង។ ហើយអ្វីដែលបានលើកឡើងនេះ អង្គជំនុំជម្រះបានជម្រាបជូនម្សិលមិញហើយថា មានមូលដ្ឋានក្នុងការពិនិត្យពិចារណាសម្រេចលើបញ្ហានេះហើយ។

បាទ ឥឡូវនេះ បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឱ្យបានមុនម៉ោងមួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ០៨:៤៦ នាទី ដល់ម៉ោង ១៣:០០ នាទី)*

[១៣:០១:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅរសៀលថ្ងៃនេះ នៅថ្ងៃព្រហស្បតិ៍ នៅថ្ងៃសុក្រ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់នូវសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនបានទទួលរងនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានអង្គជំនុំជម្រះកំណត់ធ្វើសវនាការដើម្បីស្ដាប់នូវសេចក្ដីថ្លែងការណ៍របស់ពួកគាត់។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលខ្លួនអះអាងថា បានទទួលរងនៅរសៀលនេះចំនួនពីររូប គឺមួយដែលមានរហស្សនាម 2-TCCP-982 និង 2-TCCP-985។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងមកថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មមុនគេនៅរសៀលនេះ គឺដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-982។

ជាបន្តទៅនេះ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាមដូចនេះចូលមកកាន់កន្លែងថ្លែងរៀបរាប់ទុក្ខសោកវេទនានៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៣:០៤:៤៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ**

**ស៖** សួស្ដី! លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកស្រីឈ្មោះអី?

**លោកស្រី តាក សាន់៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ តាក សាន់ នៅស្រុកគីរីវង់ ខេត្តតាកែវ។

**ស៖** អរគុណ។ ហើយលោកស្រីកើតនៅថ្ងៃ ខែ ឆ្នាំណា? លោកស្រីចាំដែរឬទេ?

**ផ៖** ខ្ញុំ ចាសខ្ញុំអត់ចាំផង ខ្ញុំមិនចេះអក្សរអត់ចាំថ្ងៃផង។

**ស៖** ចុះសព្វថ្ងៃ -- រហូតដល់ឆ្នាំនេះ តើលោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ផ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** កុំអាលទាន់ឆ្លើយតបលោកស្រី ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យភ្លើងសញ្ញាភ្លើងក្រហមសិនណា។

**ផ៖** ខ្ញុំ៦៧ឆ្នាំ។

**ស៖** អរគុណ។ ហើយលោកស្រីនៅភូមិណា ឃុំណាដែរនៃស្រុកគីរីវង់ ខេត្តតាកែវ នៅភូមិអី ឃុំអី សព្វថ្ងៃនេះ?

**ផ៖** នៅឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ។

**ស៖** លោកស្រីប្រកបមុខរបរធ្វើអីដែរសព្វថ្ងៃ?

**ផ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** កុំអាលទាន់ឆ្លើយតប!

**ផ៖** អត់មានធ្វើអីផង នាងខ្ញុំនៅតែផ្ទះសព្វថ្ងៃ រាល់ថ្ងៃ រកអុសរកអីអ៊ីចឹង លក់ដូរអ៊ីចឹងទៅ។

[១៣:០៦:៤២]

**ស៖** តើឪពុកម្ដាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ផ៖** បើឪពុកម្ដាយខ្ញុំឈ្មោះ លឹម សេង។

**ស៖** ឪពុករបស់លោកស្រីគាត់ឈ្មោះអី?

**ផ៖** ឈ្មោះ តាក។

**ស៖** ត្រកូលគាត់អីដែរ តាក ហ្នឹង?

**ផ៖** ត្រកូលគាត់ឈ្មោះ លឹម។

**ស៖** ចុះម្ដាយរបស់លោកស្រីគាត់ឈ្មោះអី?

**ផ៖** ឈ្មោះ សេង។

**ស៖** ត្រកូលរបស់ម្ដាយគាត់ឈ្មោះអី?

**ផ៖** ត្រកូលគាត់ ឪឈ្មោះ លឹម។

**ស៖** លោកស្រីមានប្ដីដែរឬទេ សព្វថ្ងៃនេះ?

**ឆ៖** ចាស នាងខ្ញុំអត់ប្ដីទេរាល់ថ្ងៃ។

**ស៖** លោកស្រីមានកូនប៉ុន្មាននាក់?

[១៣:០៨:៣៨]

**ឆ៖** សព្វថ្ងៃកូនខ្ញុំមានបួននាក់។

**ប្រធានអង្គជំនុំ៖**

សូមសួរទៅលោកស្រីបុគ្គលិកអង្គការ ធី.ភី.អូ តើលោកស្រីឈ្មោះអី?

**លោកស្រី ឆាយ ម៉ារីដែត៖**

ចាស នាងខ្ញុំឈ្មោះ ឆាយ ម៉ារីដែត គឺជាបុគ្គលិករបស់អង្គការ ធី.ភី.អូ ផ្នែកគាំទ្រផ្លូវចិត្តដល់សាក្សី និងជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី អង្គជំនុំជម្រះគ្រាន់តែសួរបញ្ជាក់លោកស្រីដើម្បីជម្រាបជូនភាគី និងសាធារណជនឲ្យបានជ្រាបថា នៅក្នុងអំឡុងពេលនៃការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនានេះ គឺរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួននេះ អង្គជំនុំជម្រះរៀបចំឲ្យមានការអង្គុយអមបាទនៅក្បែរដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីជួយសម្រួលផ្នែកខាងអារម្មណ៍របស់គាត់ដើម្បីឲ្យគាត់មានជំហររឹងមាំនៅក្នុងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់គាត់។

ហើយអរគុណចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ហើយក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសវនាការនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅលោកស្រីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រីជាអាទិ៍ ខាងផ្លូវចិត្ត ផ្លូវកាយ និងសម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យផ្ទាល់អំពីបទឧក្រិដ្ឋដែលកើតមានឡើងពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងនេះ ដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទចំនួនពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ដោយផ្ទាល់ចំពោះលោកស្រី ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ គឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

សូមអញ្ជើញលោកស្រី តាក សាន់! បាទ កុំអាលសិនលោកស្រី! លោកស្រីកុំអាលសិន។ សូមអញ្ជើញលោកស្រីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

[១៣:១១:១០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានកិត្តិយសក្នុងការចាប់ផ្តើមដំបូង បន្ទាប់មក ហើយបន្ទាប់មក ខ្ញុំនឹងផ្តល់វេទិកានេះ ជូនសហភាតារបស់ខ្ញុំក្នុងរយៈពេល៣ថ្ងៃនេះ។ យើងនឹងសួរសំណួរមួយចំនួនទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឲ្យគាត់អាចរៀបចំចម្លើយរបស់គាត់ ឆ្លើយតបទៅនឹងព្យសនកម្មដែលគាត់បានទទួលរងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំនឹងចាប់ផ្តើមសួរលោកស្រី តាក សាន់ ហើយបន្ទាប់មកទៀត លោក ឡោ ជុនធី គាត់នឹងបន្ត។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង បានសេចក្តីថា មិនប្រើសិទ្ធិក្នុងការធ្វើសេចក្តីថ្លែងរៀបរាប់ដោយខ្លួនគាត់ផ្ទាល់ទេ។ គាត់ប្រើប្រាស់សិទ្ធិរបស់គាត់ក្នុងការឆ្លើយតបនូវសំណួររបស់មេធាវីប៉ុណ្ណោះ។ អ៊ីចឹងមែនទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

ពិតហើយលោកប្រធាន គឺយើងធ្វើការជ្រើសរើសបែបនេះ គឺយើងសម្រេចចិត្តថា យើងសួរសំណួរ ហើយចម្លើយរបស់គាត់ហ្នឹង គឺជាការថ្លែងអំពីទុក្ខសោករបស់គាត់។ ចម្លើយរបស់គាត់ទៅនឹងទៅនឹងសំណួររបស់យើងខ្ញុំហ្នឹងហើយ លោកប្រធាន។

[១៣:១២:៣១]

**ប្រធានអង្គជំនុំ៖**

គ្រប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ លោកស្រីសុំការអនុវត្តបែបនេះ ឬក៏មានករណីខ្លះលើកលែងទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

ខ្ញុំគិតថា គឺខ្ញុំធ្វើបែបនេះ ចំពោះគ្រប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ សំណួរទី១ ដែលខ្ញុំចង់សួរលោកស្រី គឺខ្ញុំចង់ដឹងថា តើលោកស្រីកើតនៅឯណា? បន្ទាប់មក យើងខ្ញុំ -- យើងនឹងសួរអំពីប្រវត្តិរបស់លោកស្រីនៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ ដើម្បីជួយឲ្យលោកស្រីរៀបរាប់អំពីឃើចាប់ និងព្យសនកម្មដែលលោកស្រីបានទទួលរងនៅក្នុងសម័យនោះ។ ក៏ប៉ុន្តែដើម្បីឲ្យមានភាពច្បាស់លាស់នោះ ជាដំបូង ខ្ញុំចង់សួរលោកស្រីថា តើលោកស្រីកើតនៅឯណា? ក្នុងស្រុកណាដែរ?

[១៣:១៣:៤៣]

**លោកស្រី តាក សាន់៖**

**ឆ៖** ខ្ញុំ -- នាងខ្ញុំកើតនៅស្រុកកម្ពុជាក្រោម។

**ស៖** តើលោកស្រីអាចប្រាប់បានទេ ថានៅពេលណាដែលលោកស្រីចាកចេញពីកម្ពុជាក្រោម?

**ឆ៖** ចំនួន៦-៧ខែដែរ បាន -- ជិត១ឆ្នាំដែរហ្នឹង ខ្ញុំឡើងមក ដោយដូរឃ្សូនហ្នឹង។

**ស៖** អ៊ីចឹង ដើម្បីឲ្យច្បាស់នោះ គឺថាលោកស្រីនៅកន្លែងតែមួយទេ គឺថាលោកស្រីនៅកន្លែងភូមិកំណើតហ្នឹងតែម្ដង ឬក៏លោកស្រីផ្លាស់ទីលំនៅ ចាប់ពីពេលដែលលោកស្រីកើត និងរហូតដល់ពេលដែលលោកស្រីទៅដល់កម្ពុជាក្រោមនោះ?

**ឆ៖** ខ្ញុំ -- នាងខ្ញុំភៀសខ្លួនចេញទៅនៅឯក្រោមហ្នឹង ខ្ញុំខ្លាចពួកខាងលើហ្នឹងកៀរខ្ញុំយកទៅបាន ខ្ញុំចេះតែភៀសខ្លួនចេញទៅ នាំកូនចៅហ្នឹងចេញទៅ។

**ស៖** សូមអរគុណលោកស្រី។ តើលោកស្រីចាំទេថា នៅពេលណាដែលលោកស្រីគេចខ្លួននោះ?

**ឆ៖** មិន -- នាងខ្ញុំមិនដឹងឆ្នាំណាផង ចេះតែ -- អត់ចេះអក្សរអត់ដឹងឆ្នាំ ដឹងអីទេ។ ចេះតែភៀសខ្លួនរត់ទៅតាមគេ តាមឯងអ៊ីចឹងទៅ ខ្លាច។

**ស៖** អ៊ីចឹងមុនពេលដែលលោកស្រីភៀសខ្លួនទៅកម្ពុជាក្រោយនោះ លោកស្រីរស់នៅឯណាដែរ?

**ឆ៖** ខ្ញុំនៅភូមិគោកអំពិល ត្រពាំងឈូក គោកអំពិល។

[១៣:១៦:២៩]

**ស៖** សូមអរគុណ។ លោកស្រីបានបញ្ជាក់ថា ភៀសខ្លួនទៅជាមួយកូនទៅកម្ពុជាក្រោម។ តើ

លោកស្រីមានទុកចោលផ្ទះ ឬក៏ដីធ្លីទេ នៅពេលដែលភៀសខ្លួនហ្នឹង? លោកស្រីអាចរៀបរាប់ទេថា លោកស្រីមានទ្រព្យសម្បត្តិអ្វីខ្លះ ដែលលោកស្រីបានបោះបង់ចោលនៅពេលដែលលោកស្រីភៀសខ្លួននៅទៅកម្ពុជាក្រោមហ្នឹង?

**ឆ៖** នាង ខ្ញុំទៅមានផ្ទះ មានសម្បែង របស់អីបន្តិចបន្តួចយកទៅបាន។ ផ្ទះសម្បែងអីហ្នឹងទៅចោលអស់ហើយ។

**ស៖** សូមអរគុណ។ លោកស្រីបានបញ្ជាក់ថា លោកស្រីបានភៀសខ្លួនទៅជាមួយកូន អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកស្រីទៅកម្ពុជាក្រោមហ្នឹង មានសមាជិកគ្រួសារណាខ្លះ មានអ្នកណាខ្លះនៅក្នុងសមាជិកគ្រួសារលោកស្រីហ្នឹង ដែលទៅជាមួយលោកស្រីនុ៎ង?

**ឆ៖** ទៅម្ដាយ ទៅកូន ទៅប្ដី ទៅឪ នាំគ្នាចុះទៅហ្នឹង។

**ស៖** ហេតុអ្វីបានជាលោកស្រីភៀសខ្លួនទៅកម្ពុជាក្រោម?

**ឆ៖** ខ្ញុំខ្លាច បានខ្ញុំចេះតែភៀសខ្លួនចេញទៅហ្នឹង ខ្ញុំខ្លាចគេនាំខ្ញុំទៅលើៗទៅ ចេះតែខ្លាច ចេះតែរត់ទៅតាមគេ តាមឯងអ៊ីចឹងទៅ។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកស្រីបានឆ្លើយថា លោកស្រីបានចំណាយពេល៧ ឬ៨ខែនៅកម្ពុជាក្រោម។ អ៊ីចឹងលោកស្រីអាចរៀបរាប់បានទេថា តើលោកស្រីត្រឡប់មកកម្ពុជាវិញហ្នឹង ក្នុងកាលៈទេសៈបែបណាដែរ?

[១៣:១៨:៣៨]

**ឆ៖** ខ្ញុំត្រឡប់មកវិញហ្នឹង បានជញ្ជូនអីវ៉ាន់មកវិញហ្នឹងមកដេកនៅភ្នំដិនហ្នឹងបានចំនួន២យប់។ អ៊ីចឹងដល់រួចទៅបានពួកខ្មែរលើហ្នឹងទៅដឹកជញ្ជូនទ្រព្យរបស់យកទៅ គោរទេះអីហ្នឹងដឹកយកទៅលើអស់ យកផ្ដាយត្នោតជុំនុ៎ង។

**ស៖** តើលោកស្រីអាចផ្ដល់ព័ត៌មានបន្ថែមទេ ពាក់ព័ន្ធនឹងថា ការដូរ ដោះដូរប្រជាជនហ្នឹង តើវាប្រព្រឹត្តទៅយ៉ាងម៉េចដែរ?

**ឆ៖** ដឹងប្រព្រឹត្តយ៉ាងម៉េចដែរ ខ្ញុំបើត្រូវឲ្យទៅអ៊ីចឹងចេះតែទៅៗ មិនដឹងគិតថាម៉េច ចេះតែទៅនឹងគេនឹងឯងអ៊ីចឹងទៅ។

**ស៖** តើលោកស្រីដឹងទេថា លោកនឹងទៅដល់ -- លោកស្រីនៅពេលដែលមកដល់កម្ពុជាហ្នឹង លោកស្រីដឹងថា ខ្លួនឯងត្រូវទៅទីណាទេ?

**ឆ៖** ចាស នាងខ្ញុំមិនដឹងថាទៅណាទេ ថាបានមកដល់ភូមិស្រុកហើយ ពីតតែអរ។ ដល់រួចទៅគាត់ដឹកយកហួសទៅ។

**ស៖** អ៊ីចឹងលោកស្រីមានគិតថា ពេលមកដល់កម្ពុជាវិញហ្នឹង លោកស្រីអាចត្រឡប់ទៅភូមិកំណើតវិញបាននៅពេលនោះ?

**ឆ៖** គេអត់ឲ្យនាងខ្ញុំទៅនុ៎ងផង គេឲ្យយកខ្ញុំហួសទៅត្នោតជុំទៅ។

**ស៖** តើលោកស្រីត្រឡប់មកពីកម្ពុជាក្រោមត្រឡប់មកកម្ពុជាវិញហ្នឹង ជាមួយនឹងសមាជិកគ្រួសារហ្នឹងមានអ្នកណាខ្លះដែរ?

**ឆ៖** រទេះច្រើនណាស់ មិនដឹងអ្នកណាខ្លះទេ យើងមិនសូវស្គាល់គ្នាដែរ ប៉ុន្តែមនុស្សនៅកម្ពុជាលើទាំងអស់ មនុស្សវាច្រើន ខ្ញុំមិនអាចស្គាល់បាន។ មករទេះរាប់រយ។

[១៣:២១:២៧]

**ស៖** ខ្ញុំចង់និយាយអំពីសមាជិកគ្រួសាររបស់លោកស្រីនោះ តើមានបងប្អូនណាខ្លះដែលមកជាមួយលោកស្រីនុ៎ង?

**ឆ៖** មកម្ដាយខ្ញុំ ឪពុកខ្ញុំ កូនខ្ញុំ ប្ដីខ្ញុំ កូនចៅខ្ញុំ។

**ស៖** តើលោកស្រីមកពីកម្ពុជាក្រោមនុ៎ងមានយកទ្រព្យសម្បត្តិ គោក្របី សម្លៀកបំពាក់ អាហារអីមកតាមខ្លួនទេ?

**ឆ៖** ចាស យក។ យកមកមានគោមានរទេះអីហ្នឹង សម្ភារៈហូបហ្នឹង មាន។

**ស៖** សូមអរគុណ។ តើលោកស្រីអាចរៀបរាប់អំពីរឿងរ៉ាវដែលបានកើតឡើងនៅពេលដែលលោកស្រីមកដល់ប្រទេសកម្ពុជាបានដែរឬទេ?

**ឆ៖** នាងខ្ញុំមកដល់កម្ពុជា ខ្ញុំថា ខ្ញុំបានសម្បូរសប្បាយ បានអរ បានមកដល់កម្ពុជាខ្ញុំអរសប្បាយណាស់ ប៉ុន្តែដល់រួចទៅ ដល់ម៉េចទៅកន្លែងទុក្ខសោកទៅវិញ។

**ស៖** សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ យើងខ្ញុំព្យាយាមនិយាយអំពីការឈឺចាប់ដែលលោកស្រីបានទទួលរងនៅពេលមកដល់ប្រទេសកម្ពុជា។ តើលោកស្រីអាចជម្រាបបានទេថាពេលមកដល់ប្រទេសកម្ពុជាភ្លាមនុ៎ង លោកស្រីនៅស្រុកណាដែរ ស្រុកឃុំ?

**ឆ៖** នៅត្រពាំងធំពីខាងជើង គេហៅឃុំត្រាំកក់។

[១៣:២៣:៣៥]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចង់សួរសំណួរលោកស្រីពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលលោកស្រីយកមកតាមខ្លួន។ អ៊ីចឹងពេលដែលលោកស្រីមកដល់កម្ពុជាហ្នឹង លោកអាចរក្សាទុករបស់របរ ឬក៏ទ្រព្យសម្បត្តិដែលលោកស្រីបានយកមកពីកម្ពុជាក្រោមទេ?

**ឆ៖** ចាស នាងខ្ញុំយកបាន តែយកមកដល់រួចទៅឡានទៅដឹកជញ្ជូនយករបស់នាងខ្ញុំអស់ យកមកដាក់រួម។

**ស៖** តើលោកស្រីអាចពន្យល់ជូនអង្គជំនុំជម្រះបានទេ ថាមានរឿងអ្វីកើតឡើងក្រោយមក? តើគេឲ្យលោកស្រីរស់នៅជាមួយក្រុមគ្រួសារ ឧទាហរណ៍ដូចជាមួយប្ដី និងជាមួយកូនរបស់លោកស្រីទេ?

**ឆ៖** មុនដំបូងគេឲ្យនៅ ដល់យូរទៅគេបំបែកជាកងជាក្រុមអ៊ីចឹងទៅ។

**ស៖** តើលោកស្រីអាចមើលថែទាំកូនទេ? ហើយអាចពន្យល់បានទេថាតើហេតុការណ៍ហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** បានពន្យល់ប្រាប់ដែរថា កូនចៅហ្នឹងកុំមាត់កុំកអីឲ្យសោះ ខ្លាច ធ្វើអីចេះតែធ្វើទៅកូន។ បានណែនាំកូនអ៊ីចឹងដែរ។

**ស៖** តើលោកស្រីអាចទៅជួបកូនហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** នាងខ្ញុំមិនបានទៅជួបទេ តែកូនថ្ងៃ១០ ថ្ងៃ២០ អីកូនមកលេង។ យូរម្ដងម្កាលហ្នឹង បីបួនដប់ថ្ងៃហ្នឹងមកលេង មកជួបខ្ញុំម្ដង។

[១៣:២៦:០៨]

**ស៖** តើលោកស្រីមានការឈឺចាប់ទេ ដែលមិនអាចជួបកូនបានញឹកញាប់បែបនេះនោះ។ អ៊ីចឹងតើពេលនុ៎ងតើអារម្មណ៍លោកស្រីឈឺចាប់បែបណាដែរ?

**ឆ៖** នឹកឃើញកូន ហើយនិងម្ដាយហ្នឹងស្រឡាញ់កូន ហើយកូនមិនបានជួប កូនទៅឆ្ងាយពីភ្នែកម្ល៉ោះហើយចេះតែនឹកកូនអ៊ីចឹងទៅ មិនដឹងធ្វើម៉េច។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកស្រីថា បានមកដល់ត្រាំកក់ជាមួយកូនពីរនាក់។ តើលោកស្រីមានកូនផ្សេងទៀតទេ នៅពេលដែលលោកស្រីមកដល់ត្រាំកក់ហ្នឹង ឬក៏តែពីរនាក់ហ្នឹងទេ?

**ឆ៖** ខ្ញុំមានកូនមួយទៀត ពោះធំ។ ដល់រួចទៅមុនហ្នឹងយកប្ដីខ្ញុំទៅបាត់ទៅ មិនដឹងយកទៅឯណា ហើយខ្ញុំកូនង៉ែតតែម្នាក់ឯងនៅក្នុងពេទ្យ។

**ស៖** សូមអរគុណ។ តើលោកស្រីអាចរៀបរាប់ឲ្យបានលម្អិតបន្តិចបានទេ អំពីការបាត់ខ្លួន

របស់ប្ដីលោកស្រី តើគាត់បាត់ខ្លួនក្នុងកាលៈទេសៈបែបណា? ហើយពេលដែលបាត់ខ្លួនហ្នឹង បាត់តែគាត់ម្នាក់ទេ ឬក៏មានអ្នកផ្សេងទៀតបាត់ដែរនៅក្នុងគ្រួសារលោកស្រីហ្នឹង?

**ឆ៖** ចាស ប្ដីខ្ញុំទៅរទេះបីបួនប្រាំប្រាំមួយហ្នឹង បាត់ទាំងអស់។ ពេលម៉ោងប្រាំឡើងមក ឃើញតែគោបាត់ប្ដីខ្ញុំ ឃើញរទេះឃើញអីមក បាត់អស់រលីង។ ហើយខ្ញុំក៏ខ្ញុំមិនបានសួរទៀត មិនបានសួរប្ដីខ្ញុំថាទៅណាមកណា ខ្ញុំមិនបានសួរទេ ខ្ញុំខ្លាច។

**ស៖** លោកស្រីបានរៀបរាប់អំពីកូនពីរនាក់នៅសម័យនោះ អ៊ីចឹង តើកូនទាំងពីរនាក់ហ្នឹងនៅរស់ទេ?

[១៣:២៨:៣៩]

**ឆ៖** ចាស នៅរស់។

**ស៖** តើលោកស្រីមានបាត់បង់សាច់ញាតិណាផ្សេងទៀតទេ នៅក្នុងរបបខ្មែរក្រហមនោះ?

**ឆ៖** ខ្ញុំបាត់ពោះមួយខ្ញុំដែរ។ ពោះមួយខ្ញុំបាត់នៅកាលនុ៎ងដែរ។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងនឹងនិយាយអំពីការឈឺចាប់ជាយថាហេតុដែលលោកស្រីបានទទួលរងនៅពេលដែលលោកស្រីធ្វើការនៅត្រាំកក់។ ខ្ញុំចង់ឲ្យលោកស្រីរៀបរាប់ថា គេចាត់តាំងឲ្យលោកស្រីធ្វើការនៅឯណា នៅត្រាំកក់? ហើយការងារដែលលោកស្រីត្រូវធ្វើនុ៎ងមានអ្វីខ្លះដែរ?

**ឆ៖** ខ្ញុំ -- គេឲ្យខ្ញុំ -- មុនដំបូងឲ្យខ្ញុំរែកដីដំបូកចាក់ស្រែ ធ្វើជីរ។ ហើយដល់ក្រោយមក ឲ្យខ្ញុំទៅធ្វើប្រឡាយគោកគ្រួស។

**ស៖** តើការងារដែលលំបាកជាងគេបំផុតសម្រាប់លោកស្រីនៅពេលនោះ គឺការងារអ្វីដែរ?

**ឆ៖** ការងាររែកដីដំបូក។ គេឲ្យខ្ញុំរែកឡើង រែកប្រឡាយតាមប្រឡាយគោកគ្រួសហ្នឹង គេឲ្យខ្ញុំរែក ហើយគេតប់ដីពីលើបង្គីហ្នឹងទៀត ឲ្យខ្ញុំរែកធ្លាក់ជ្រោះ ធ្លាក់ស្ពាន ធ្លាក់ៗអីៗអ៊ីចឹង។

**ស៖** តើលោកស្រីអាចសម្រាកបានទេ នៅពេលដែលលោកស្រីហត់ហ្នឹងក្នុងពេលធ្វើការហ្នឹង?

**ឆ៖** ចាស ខ្ញុំមិនបានសម្រាកទេ។ គេបង្ខំឲ្យធ្វើ គេធ្វើគ្រប់គ្នាមិនបានសម្រាក។

[១៣:៣១:១៥]

**ស៖** ហេតុអ្វីបានជាលោកស្រីមិនបានសម្រាក?

**ឆ៖** គេមិនឲ្យយើងសម្រាក ឲ្យខំធ្វើ រកឲ្យឆាប់ហើយ។

**ស៖** តើលោកស្រីធ្លាប់ធ្វើការនៅពេលយប់ទេ បន្ទាប់ពីហូបបាយពេលល្ងាចហើយហ្នឹងនៅ

ពេលដែលលោកស្រីនៅត្រាំកក់?

**ផ៖** ចាស គេឲ្យនាងខ្ញុំហូបបាយហើយហ្នឹង ឲ្យកាប់រណ្ដៅដាំដូង។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកស្រីបានឆ្លើយថា លោកស្រីមានផ្ទៃពោះនៅពេលដែលនៅត្រាំកក់។ អ៊ីចឹងនៅពេលដែលលោកស្រីមានផ្ទៃពោះហ្នឹង តើគេឲ្យធ្វើការទេ?

**ផ៖** នាងខ្ញុំធ្វើដល់តែកើត ឲ្យដេរស្លឹក ដេរអីហ្នឹងទាល់តែកើត ធ្វើការស្រាលហ្នឹងដេរស្លឹក។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំចង់ដឹងថា ការងារដែលលំបាកលំបិនបំផុតដែលលោកស្រីធ្វើនៅត្រាំកក់ហ្នឹង តើការងារណាដែរ ដែលលោកស្រីគិតថា វាមានការលំបាកបំផុតសម្រាប់លោកស្រីនោះ?

**ផ៖** ការងារលំបាកបំផុត គឺរែកដីហ្នឹងតែម្ដង។ វាតប់ឲ្យធ្ងន់ពេក។ ជួនណាគេមិនតប់ទៅ ជួនណាគេតប់ទៅ។ យើងរែកអានាសៗហ្នឹង។

**ស៖** សូមអរគុណ។ តើលោកស្រីមានទទួលរងនូវភាពអត់ឃ្លានទេ នៅពេលដែលលោកស្រីធ្វើការនៅត្រាំកក់ហ្នឹង?

**ផ៖** ចាស ហូបបបរ។

**ស៖** តើបបរហ្នឹងគ្រប់គ្រាន់ទេ? បានន័យថា ឲ្យលោកស្រីហូបចុកឆ្អែតទេបបរហ្នឹង?

**ផ៖** ចាស អត់ឆ្អែតទេ។ ខ្លាចកូនអត់ឆ្អែតផ្សំយកទៅឲ្យកូនខ្លះទៀត ហូបសន្សំសំចៃអ៊ីចឹង ឲ្យកូនឆ្អែត។

[១៣:៣៤:១៤]

**ស៖** អ៊ីចឹងខ្ញុំចង់សួរឲ្យច្បាស់តែម្ដងថា នៅពេលហ្នឹង តើលោកស្រីឃ្លានទេ?

**ផ៖** ចាស ឃ្លាន លួចក៏មិនបាន ខ្លាច ចេះតែទ្រាំទៅ។

**ស៖** ហេតុអីបានជាលោកស្រីខ្លាច?

**ផ៖** នាងខ្ញុំ ខ្លាចគេយកទៅវ៉ៃចោល ខ្លាចទៅ ហូបមិនឆ្អែតមិនបានរអ៊ូ។

**ស៖** តើលោកស្រីទទួលបានរបបអាហារដូចគ្នាដដែលៗ ឬក៏មានការផ្លាស់ប្ដូរបន្ទាប់ពីរស់នៅបានប៉ុន្មានខែ ប៉ុន្មានឆ្នាំមកនៅត្រាំកក់នោះ?

**ផ៖** ផ្លាស់ប្ដូរបន្ថែមបន្តិចបន្តួច ប៉ុន្តែស្លនៅតែទឹកច្រើនតែដដែល ទឹកកក្លកតែដដែលហ្នឹង ហូបមិនឆ្អែតទេ យកមកចែកគ្នាមួយតុប្អូននាក់ហ្នឹងអង្គុយជាជួរ។

**ស៖** អម្បាញ់មិញនេះ លោកស្រីឆ្លើយថាលោកស្រីបានលាក់បបរទុកសម្រាប់ឲ្យកូន--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ លោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំបានតាមដានស្តាប់ការតាំងសំណួរពីសហមេធាវីនាំមុខមកកាន់ដើមបណ្តឹងរដ្ឋប្បវេណីមួយរយៈមកហើយនេះ។ ខ្ញុំថាមានភាសិតអាមេរិកាំងមួយនិយាយថាគឺថា “ដើរឬក៏ហែលទឹកដូចទា” បាទ “ដើរដូចទា ហែលទឹកដូចទា”។ អ្វីដែលខ្ញុំស្តាប់សក្ខីកម្មនេះ គឺគាត់សួរឲ្យដើមបណ្តឹងរដ្ឋប្បវេណីផ្តល់នូវសក្ខីកម្ម ខ្ញុំអ្វីដែលខ្ញុំចង់បាននោះ គឺថាយើងគឺមិនបានសួរអំពីការឈឺចាប់របស់ជនរងគ្រោះ ឬក៏យ៉ាងណានោះទេ។ យើងមានការពិភាក្សាគ្នាពីមុនជាយូរមកហើយជុំវិញអ្វីដែលយើងត្រូវធ្វើការតាំងសំណួរនៅថ្ងៃនេះ។ យើងខ្ញុំ យើងដែលកំពុងតែស្តាប់សក្ខីកម្មនោះ ខ្ញុំគិតឃើញថាមិនមែនជាៗអ្វីដែលៗត្រូវតែធ្វើដែលៗៗត្រូវធ្វើទេ។

[១៣:៣៧:៣៤]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ ខ្ញុំមានការភ្ញាក់ផ្អើលណាស់ចំពោះការជំទាស់របស់លោកមេធាវីកូប៉េ នេះ។ ក្នុងរយៈកន្លះម៉ោងកន្លងមកនេះ ដើមបណ្តឹងរដ្ឋប្បវេណីគាត់បានបញ្ជាក់ថាគាត់បាត់ផ្ទះ បាត់បង់ប្តី បានឃើញកូនស្លាប់ដោយសារការឃ្លាន ហើយគាត់ក៏ឃ្លាន ហើយគាត់បានធ្វើការក្នុងលក្ខខណ្ឌអមនុស្សធម៌។ អ៊ីចឹងតើចំណុចនេះមិនមែនជាការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីទេឬ? គាត់ជាអ្នកមិនចេះអក្សរទេ អ៊ីចឹងបើសិនជាគាត់ចេះតែនិយាយទៅ គឺថាពិបាកណាស់ អ៊ីចឹងហើយខ្ញុំសួរសំណួរនេះ ដើម្បីឲ្យគាត់អាចងាយស្រួលក្នុងការនិយាយ។ អ៊ីចឹងលោកតើលោកគិតថាសក្ខីកម្មរបស់គាត់យ៉ាងម៉េចដើម្បីឲ្យមានការឈឺចាប់នោះ? ខ្ញុំមានការភ្ញាក់ផ្អើលមែនទែន នៅពេលដែលលោកមេធាវីជំទាស់បែបនេះនោះ អ៊ីចឹងខ្ញុំសួរគាត់វិញ ថាតើជាការឈឺចាប់ ហើយនិងការព្យសនកម្មរបស់គាត់ហ្នឹងយ៉ាងម៉េចដែរ ពីព្រោះថាគាត់ៗទើបតែរៀបរាប់ហើយទេ។

[១៣:៣៨:៤៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤២:១០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនទៅចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីសម្រេចលើសេចក្តីជំទាស់របស់មេធាវីការពារក្តី អំពីវិធីសាស្ត្រក្នុងការតាំងសំណួររបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺខ្ញុំមានការកត់សម្គាល់ទៅលើភាសាដែលពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលនិយាយអំពីការឈឺចាប់។ គឺថាត្រូវតាំងសំណួរឲ្យល្អបំផុត។ និយាយអំពីខ្លឹមសារវិញ ជាក់ស្តែងហើយ គឺថាដើមបណ្តឹងរដ្ឋប្បវេណីកំពុងនិយាយអំពីការឈឺចាប់។ វាពិបាកក្នុងការញែកឲ្យដាច់ពីគ្នាឲ្យបានច្បាស់រវាងសក្ខីកម្មអំពីការឈឺចាប់ និងសក្ខីកម្មអំពីអង្គហេតុ។

សម្រាប់២ថ្ងៃកន្លះខាងមុខ គឺថាយើងធ្វើទៅតាមការអនុវត្តជាក់ស្តែងដែលបានរៀបចំរួចហើយដែលត្រូវតាំងសំណួរដោយសហមេធាវីនាំមុខ។ នៅពេលដែលត្រូវសួរទៅដល់ភាគីដទៃទៀតនោះ យើងត្រូវឲ្យមាន -- បើកចំហឲ្យដាក់សំណើពាក់ព័ន្ធទៅនឹង បង្ហាញនូវហេតុផលណាមួយ។ ហើយសម្រាប់២ថ្ងៃ ឬក៏២ថ្ងៃកន្លះខាងមុខនេះ អង្គជំនុំជម្រះបើចាំបាច់ និងពិនិត្យឡើងវិញអំពីវិធីសាស្ត្រពាក់ព័ន្ធទៅនឹងភស្តុតាងសម្រាប់បញ្ហានេះ ក៏ប៉ុន្តែសម្រាប់ពេលនេះ គឺថាសូមបន្តទៅមុខ ដូចដែលបានរៀបចំរួចជាស្រេចហើយ។ ហើយសូមមេត្តាកុំរំខានដល់ភាគីដទៃទៀត ចាំដល់ពេលឱកាសរបស់ខ្លួន កុំរំខានដល់ការតាំងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

[១៣:៤៤:២៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំជិតចប់ទៅហើយអម្បាញ់មិញនេះ។ នៅពេលដែលគាត់កាត់ផ្តាច់នោះ។ អ៊ីចឹង គាត់អាចពន្យល់បាន ថាគាត់ជំទាស់ហ្នឹង វាមានហេតុផលយ៉ាងម៉េច តែចំពោះខ្ញុំនោះ ខ្ញុំភ្ញាក់ផ្អើលណាស់ នៅពេលដែលគាត់ជំទាស់បែបហ្នឹងនោះ។ ខ្ញុំគិតថា ការជំទាស់ចុងក្រោយអម្បាញ់មិញនេះ គឺថាៗវាមិនសមហេតុផលទេ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំនឹងបញ្ចប់ ដើម្បីឲ្យលោកស្រីមានឱកាសក្នុងការបង្ហាញអំពីការឈឺចាប់របស់ខ្លួន។ តើក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យនោះ ក្រោយពេលវៀតណាម

ចូលមកដល់នោះ តើលោកស្រីទៅណាដែរ?

**លោកស្រី តាក សាន់៖**

**ឆ៖** ចូល -- យៀកណាមចូលមកហ្នឹង នាងខ្ញុំទៅតាមពួករទេះពួកខ្មែរក្រហមនុំង ដល់រួចខ្ញុំតាមទៅថា ខ្ញុំកូនង៉ែតហើយ បីកូនង៉ែតហើយអង្គាល់នុំង។ ដល់រួចខ្ញុំទៅថា បានអង្ករ បានអីហូបអីចឹងទៅ ដល់ទៅឆ្ងាយទៅៗ គេដេញឲ្យខ្ញុំថយមកក្រោយវិញមក។ ខ្ញុំក៏មករកម៉ែឪខ្ញុំទៅ។

**ស៖** តើលោកស្រីមានត្រឡប់មកភូមិកំណើតវិញទេ?

**ឆ៖** អង្កាល់យួនចូលទៅហើយបាននាំគ្នាចុះមកស្រុកមកភូមិមកកំណើតវិញទៅ ទាំងអស់គ្នាហ្នឹង នាំគ្នាចុះមកដើរផង ដេកតាមផ្លូវផង អ៊ីចឹងទៅ យប់ត្រឹមម៉ានដេកត្រឹមហ្នឹង។

[១៣:៤៦:២៥]

**ស៖** តើលោកស្រីអាចរកឃើញផ្ទះ ដែលលោកស្រីបានរស់នៅមុនរបបកម្ពុជាប្រជាធិបតេយ្យវិញទេ?

**ឆ៖** ចាស អត់មានឃើញទេ។ អត់ឃើញ បាត់បងអស់រលីងផ្ទះ។

**ស៖** អម្បាញ់មិញនេះ លោកស្រីបានឆ្លើយថា បានបាត់បង់ប្ដីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើក្រោយមកទៀតនោះ លោកស្រីមានរៀបការម្ដងទៀតទេ? ហើយនៅពេលដែលលោកស្រីមិនមានប្ដីបែបនេះ តើលោកស្រីមានការលំបាកក្នុងការរស់នៅបែបណាដែរ?

**ឆ៖** ចាស នាងខ្ញុំលំបាកដែរ គ្រាន់ខ្ញុំថា ខ្ញុំអត់យកប្ដីទៀតហ្នឹង ខ្ញុំនៅតែជាមួយកូនអ៊ីចឹងទៅ។ នាងខ្ញុំឈប់យក និយាយទៅខ្ញុំនឹកតែប្ដីខ្ញុំហ្នឹង បានតែខ្ញុំឈប់យក។

**ស៖** តើលោកស្រីមានការឈឺចាប់ទេ ដោយលោកស្រីមិនស្គាល់អំពីកន្លែងដែលសាច់ញាតិស្លាប់នោះ? ហើយបន្ទាប់មកទៀតនោះ តើលោកស្រីមានបានរៀបចំធ្វើពិធីបុណ្យឧទ្ទិសកុសលបង្សុកូលអីទៅដល់សាច់ញាតិហ្នឹងទេ?

**ឆ៖** ចាស នាងខ្ញុំដល់ខែបុណ្យខែទាន ខ្ញុំដុតធូកដុតអីឧទ្ទិសទៅដែរ ប៉ុន្តែមិនដឹងប្ដីខ្ញុំស្លាប់នៅឯណា អីឯណាខ្ញុំមិនដឹង។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១៣:៤៨:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសួរតែពី១០ទៅ១៥នាទីទេ។ សួរសំណួរបន្តទៅដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅពេលដែលគាត់រាងធូរអារម្មណ៍បន្តិច ខ្ញុំនឹងសួរគាត់។ បាទ បើសិនជាលោកប្រធានអនុញ្ញាតលោកប្រធាន ខ្ញុំសូមសួរពី១០ទៅ១៥នាទី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ លោកស្រី ខ្ញុំឈ្មោះ វ៉ាំងសង់ ដេស្មាឯល សូមចោទសំណួរពីរបីសំណួរ។ ជួសមុខឲ្យការិយាល័យសហព្រះរាជអាជ្ញា ហើយនិងសូមបំភ្លឺចំណុចមួយចំនួន ជាពិសេសអម្បាញ់មិញនោះ គឺតាមរយៈការបកប្រែជាភាសាបារាំង ខ្ញុំឮថា លោកស្រីកើតនៅប្រទេសកម្ពុជាក្រោម ហើយលោកស្រីនិយាយពីភូមិកំណើតរបស់លោកស្រីដែលស្ថិតនៅប្រទេសកម្ពុជា។ អ៊ីចឹងតើលោកស្រីអាចនិយាយឡើងវិញបានទេ ថាតើលោកស្រីកើតនៅកន្លែងណាជាក់លាក់ នៅប្រទេសវៀតណាម ឬក៏នៅប្រទេសកម្ពុជា?

**លោកស្រី តាក សាន់៖**

**ឆ៖** ប្រទេសកម្ពុជា នាងខ្ញុំ។

**ស៖** តើលោកស្រីអាចជម្រាបឈ្មោះភូមិ ហើយនិងឃុំដែលលោកស្រីកើតបានដែរឬទេ?

**ឆ៖** គេហៅភូមិត្រពាំងឈូក គោកអំពិល តែស្រុកមិនដឹងស្រុកអីផង ខ្ញុំមិនបានដឹងស្រុក គេហៅស្រុកអី ឮតែហៅថាត្រពាំងឈូក គោកអំពិលអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងលោកស្រីបានចេញទៅកម្ពុជាក្រោម ហើយនៅពេលណាមួយនោះ លោកស្រីបានត្រឡប់មកប្រទេសកម្ពុជាវិញ។ លោកស្រីឆ្លើយនៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់លោកស្រី គឺឯកសារ D22/3205 គឺលោកស្រីកត់ឈ្មោះលោកស្រីនៅក្នុងបញ្ជីមួយដែលរដ្ឋាភិបាលវៀតណាមបានធ្វើ ដើម្បីប្ដូរដោះដូរខ្មែរដែររស់នៅប្រទេសវៀតណាមជាមួយនឹងជនជាតិ

វៀតណាមដែលរស់នៅស្រុកខ្មែរ។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៣:៥១:២៦]

**ឆ៖** ចាស នាងខ្ញុំដូរជាមួយវៀតណាមលើកទី២។

**ស៖** បាទនៅក្នុងទម្រង់បែបបទហ្នឹងមានកាលបរិច្ឆេទមួយ ទៅដើមឆ្នាំ១៩៧៦ តើនៅពេលហ្នឹងហើយឬដែលលោកស្រីបានត្រឡប់មកប្រទេសកម្ពុជាវិញ? លោកស្រីអាចឆ្លើយបញ្ជាក់បានទេថា នៅដើមឆ្នាំ៧៦ហ្នឹងហើយដែលលោកស្រីត្រឡប់មកប្រទេសកម្ពុជាវិញ?

**ឆ៖** ចាស នាងខ្ញុំមកដល់នុំងវាឡើងទៅលើហួសទៅ ខ្ញុំមិនបានមកដល់ស្រុកកំណើតទេ ឡើងទៅផ្លាយអំពកបែក ហៅថាភូមិត្រាំកក់ហ្នឹងទៅ។

**ស៖** ក៏ប៉ុន្តែមកនឹងទៅដល់ខាងជើងស្រុកត្រាំកក់នោះ លោកស្រីបាននិយាយថា លោកស្រីបានមកឆ្លងកាត់តាមភ្នំដិន បន្ទាប់ពីឆ្លងព្រំដែនថៃ -- វៀតណាម-ខ្មែរ។ តើលោកស្រីអាចប្រាប់បានទេ តើលោកស្រីបានស្នាក់នៅភ្នំដិនរយៈពេលប៉ុន្មានថ្ងៃ? ប៉ុន្មានថ្ងៃ ឬក៏ប៉ុន្មានខែនៅភ្នំដិននោះ?

**ឆ៖** ចាស នាងខ្ញុំនៅបាន២យប់ នៅ២យប់ ដាំបាយដាំអីហូបនៅនុំងភ្នំដិននុំង ហើយក៏ស្អែកឡើងអ៊ីចឹងបានគេយកឡានហ្នឹងទៅដឹកទ្រព្យរបស់គោពពែអីមក ហើយនាងខ្ញុំហ្នឹងមកគ្នាទាំងអស់ហ្នឹងមក។

**ស៖** នៅពេលដែលគេនាំលោកស្រីទៅនោះ គឺថាសុទ្ធតែជាអ្នកដែលគេនាំមកពីវៀតណាមតាមឡានធំហ្នឹង ឬក៏មានប្រជាជនថ្មី គឺប្រជាជន១៧មេសា ដែលមកជាមួយលោកស្រីដែរ?

[១៣:៥៣:៤៨]

**ឆ៖** មានថ្មីមានចាស់ ហើយមកតែនាងខ្ញុំហ្នឹងមកគ្នាខ្ញុំហ្នឹងចំនួនច្រើនរទេះអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ លោកស្រីបាននិយាយថា លោកស្រីមកដល់ភូមិត្នោតជុំ ឃុំខ្ពបត្របែកនៅស្រុកត្រាំកក់។ លោកស្រីបាននិយាយពីកិច្ចប្រជុំមួយនៅក្នុងទម្រង់បែបបទរបស់លោកស្រីដែលថានៅក្នុងកិច្ចប្រជុំនោះ គឺលោកស្រីបាននិយាយថា គេបានដកហូតយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់លោកស្រី។ នៅក្នុងទម្រង់បែបបទនោះដដែល លោកស្រីបានប្រាប់ថា លោកស្រីត្រូវបានគំរាមថា "បើសិនជាអង្គការដឹងថា មានអ្នកណាម្នាក់លួចលាក់ទ្រព្យសម្បត្តិរបស់ខ្លួន នឹងត្រូវបានគេចាត់ទុកថាជាខ្មាំង"។ តើនេះជាលើកទី១ ហើយឬដែលគេគំរាមលោកស្រីពេលដែលត្រឡប់មកប្រទេសកម្ពុជាវិញ? គេនិយាយថា បើសិនជាអ្នកណាមិនព្រមដាក់ទ្រព្យសម្បត្តិជារួម ត្រូវបានចាត់ទុកថាជាខ្មាំង។ ជាលើក

ទី១ ឬយ៉ាងណា?

**ឆ៖** ចាស ជាលើកទី១ ឲ្យប្រមូលយកទៅឲ្យអស់ទ្រព្យសម្បត្តិដែលយកទៅទាំងប៉ុន្មានហ្នឹង នាំគ្នាយកចូលទៅដាក់រួមឲ្យអស់។

**ស៖** នៅពេលដែលលោកស្រីត្រូវដាក់ទ្រព្យសម្បត្តិដាក់រួមនោះ តើលោកស្រីមានសោកស្ដាយដែរឬទេ ដែលបានត្រឡប់ចូលមកកាន់ប្រទេសកម្ពុជាវិញនោះ?

[១៣:៥៥:៤៤]

**ឆ៖** សោកស្ដាយដែរ ដែលយកទៅថាបានហូប ហើយដល់រួចទៅយកដាក់ជារួម ស្ដាយដែរ ដូចជា គោពពែអី។

**ស៖** បន្ទាប់មកទៀត គេបានដាក់លោកស្រីចូលទៅក្នុងអង្គភាពមួយនៃសហករណ៍។ តើនៅក្នុងកងហ្នឹង អ្នកណាធ្វើការជាមួយលោកស្រីខ្លះ? អ្នកដែលមកពីវៀតណាមជាមួយលោកស្រី ឬក៏ប្រជាជន ១៧មេសា ឬក៏ប្រជាជនមូលដ្ឋាន? តើគេដាក់ឲ្យមនុស្សនៅធ្វើការឡូកឡំ ជាមួយគ្នាដែរឬទេ?

**ឆ៖** ចាស ដាក់នាងខ្ញុំហ្នឹងដាក់ឡូកឡំគ្នាទាំងអស់ ទាំងគ្នាហ្នឹង។

**ស៖** លោកស្រីចង់និយាយថា ប្រជាជនមូលដ្ឋានហ្នឹងក៏នៅធ្វើការជាមួយលោកស្រីក្នុងកងលោកស្រីដែរ ឬក៏មានតែប្រជាជនថ្មីទេ ដែលធ្វើការជាមួយលោកស្រី? លោកស្រីអាចបញ្ជាក់ចំណុចនេះបានដែរឬទេ?

**ឆ៖** មានៗខ្លះ មាននៅធ្វើបីបួនប្រាំនាក់អ៊ីចឹងទៅ ប៉ុន្តែពួកខ្ញុំប្រឹងប្រែងជាងគេ គេអ្នកមូលដ្ឋានគេមិនសូវប្រឹងទេ។

**ស៖** តើកងដែលលោកស្រីធ្វើការនោះ អ្នកណាគេជាអ្នក -- ជាប្រធាន? តើប្រជាជនមូលដ្ឋានជាប្រធាន ឬក៏ជាអ្នកថ្មីដែលមកដូចជាលោកស្រីអ៊ីចឹងដែរ?

**ឆ៖** មូលដ្ឋាន ខ្ញុំមិនស្គាល់ផង។

[១៣:៥៧:៥៣]

**ស៖** លោកស្រីបានឆ្លើយនៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះថា បើសិនជាលោកស្រីមិនអាចបញ្ចប់ការងារដែលគេដាក់ឲ្យលោកស្រីបាននោះទេ នោះគឺនៅក្នុង -- នៅវាលស្រែគឺថាឲ្យស្ទូងគ្រប់ចំនួននោះ លោកស្រីមិនបានរបបអាហារទេ។ តើលោកស្រីធ្លាប់ត្រូវបានគេបង្អត់អាហារដែរឬទេ នៅពេលដែលលោកស្រីបំពេញការងាររបស់ខ្លួនមិនចប់នោះ? ឬក៏គ្រាន់តែជាពាក្យគំរាមចោលអ៊ីចឹងទេ?

**ឆ៖** ចាស នាងខ្ញុំគេគ្រាន់តែគំរាមហ្នឹង តែហូបគេឲ្យនៅឲ្យហូបអ៊ីចឹង ប៉ុន្តែវាហូបមិនឆ្អែតគ្រប់គ្រាន់ទេ។

**ស៖** លោកស្រីក៏បានលើកឡើងផងដែរថា លោកស្រីបានធ្វើជីរដែល -- ជីរលាមក ត្រូវធ្វើយ៉ាងណាកុំឲ្យវាប្រែពេក ព្រោះកាលណាប្រែពេកអាចធ្វើឲ្យសំណាបនោះងាប់។ តើហេតុអ្វីបានជាលោកស្រីត្រូវភ្លក់ជីរលាមកនោះ ដើម្បីឲ្យដឹងថា ជីរហ្នឹងមិនប្រែពេកទេ មិនអាចឲ្យស្រូវងាប់? លោកស្រីម៉េចក៏ភ្លក់ជីរលាមកហ្នឹង?

**ឆ៖** ចាស នាងខ្ញុំ គេប្រើខ្ញុំឲ្យភ្លក់ហើយ ខ្ញុំចេះតែភ្លក់ទៅ ខ្ញុំខ្លាចគេធ្វើបាបខ្ញុំ។

**ស៖** ចុះបើសិនជាសន្ទូងនោះងាប់នោះ តើមានរឿងអ្វីកើតឡើងចំពោះលោកស្រីដែរ បើតាមបទបញ្ជារបស់ខ្មែរក្រហមនោះ?

[១៣:៥៩:២៣]

**ឆ៖** តែងាប់ គេយកយើងធ្វើទណ្ឌកម្មអ៊ីចឹងទៅ ប្រែពេក។

**ស៖** លោកស្រីនៅក្នុងសំណុំរឿងមានឯកសារមួយដែលមានលេខ E3/4092 គឺជាឯកសារដែលចេញមកពីមន្ទីរសន្តិសុខក្រាំងតាចាន់។ បាទ ខ្ញុំនឹងមិនបង្ហាញឯកសារនេះទៅជូនលោកស្រីទេ ក៏ប៉ុន្តែខ្ញុំនឹងអានសម្រង់មួយផ្នែកមួយនៅទំព័រទី២ ជាភាសាខ្មែរគឺ ERN លេខ 0--

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ មានការតវ៉ាពីភាគីមេធាវីការពារក្តី។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់អំពីការបង្គាប់ពីចៅក្រម ហ្វេនស៍។ ប៉ុន្តែខ្ញុំត្រូវក្រោកឈរឡើងនេះដោយសារខ្ញុំគិតថា យើងកំពុងតែបោះមួយជំហានទៅមុខទៀតហើយដែលការបង្ហាញឯកសារទៅដើមបណ្តឹងរដ្ឋប្បវេណី ហើយសូមឲ្យឆ្លើយថា មានប្រតិកម្មយ៉ាងម៉េចពាក់ព័ន្ធទៅនឹងចម្លើយរបស់គាត់។ គឺថា ដែលមិនពាក់ព័ន្ធទៅនឹងការឈឺចាប់ទេ ប៉ុន្តែជាបំណងដើម្បីបង្កើតនូវអង្គហេតុ បង្កើតនូវភស្តុតាង។ ដូច្នេះ ខ្ញុំមានកាតព្វកិច្ចត្រូវជំទាស់ទៅនឹងការតាំងសំណួរ ការបង្ហាញឯកសារបែបនេះ។ ដូចដែលខ្ញុំបានលើកឡើងអំពីសុភាសិតមួយហើយ ការប្រើសុភាសិតហ្នឹង គឺមានបំណងនិយាយសំដៅថាដើមបណ្តឹង -- ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាមេធាវីទេ។

[១៤:០១:៤៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំខ្លាចថា ការបកប្រែទៅជាបារាំងកាន់តែពិបាកទៀតហើយ កាលណាលោកប្រើភាសា ឬ ភាសិតបែបហ្នឹង ដែលម្នាក់ៗគេត្រូវពិចារណាដើម្បីយល់ឲ្យបាននោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំត្រូវ -- វាជាឃ្លារបស់ភាសិតរបស់អាមេរិកាំង ខ្ញុំឈប់ប្រើទៀតហើយ។ បាទ គឺខ្ញុំសំដៅទៅលើខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចំពោះភាសិតមួយនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំគិតថា ការជំទាស់នេះមិនសមស្របនោះទេ ព្រោះថាដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ច្បាស់ហើយ គឺថាការឈឺចាប់របស់ខ្លួនមួយគត់គឺថា ដោយសារខ្លួនមិនដឹងថាក្រុមគ្រួសារខ្លួនត្រូវបានគេនាំយកទៅកន្លែងណា ហើយស្លាប់នៅកន្លែងណា។ ខ្ញុំគ្រាន់តែព្យាយាមចង់ដឹងថា តើគាត់អាចស្គាល់អ្នកណាម្នាក់ ឬក៏កំណត់អត្តសញ្ញាណរបស់អ្នកណាម្នាក់ដែលបានធ្លាក់ខ្លួនទៅមន្ទីរក្រាំងតាចាន់ តែប៉ុណ្ណឹងទេលោកប្រធាន កាលដែលខ្ញុំចង់លើកពីឯកសារ និងសម្រង់អម្បាញ់មិញនេះ។

[១៤:០៣:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៣:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់អង្គជំនុំជម្រះបដិសេធសេចក្តីជំទាស់របស់មេធាវីការពារក្តីលោក នួន ជា។ សហព្រះរាជអាជ្ញាអន្តរជាតិបន្តការតាំងសំណួរឲ្យបានចប់សព្វគ្រប់ ហើយឲ្យដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបនឹងសំណួរ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ ខ្ញុំសូមរំឭកលេខ ERN គឺថាឯកសារ E3/4092 ជាភាសាខ្មែរគឺទំព័រ ERN 00271133, ជាភាសាអង់គ្លេសគឺ 00834793, ជាភាសាបារាំងគឺថា 00721274។ បាទ នៅក្នុងឯកសារនេះ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី គឺជាឯកសារដែលចេញមកពីមន្ទីរសន្តិសុខក្រាំងតាចាន់។ គេនិយាយអំពីមនុស្សម្នាក់ដែលមានឈ្មោះថា តាក ស៊ីម កាលនោះគាត់មានអាយុ ៣៦ឆ្នាំ គាត់រៀបការ

ជាមួយនឹង ង៉ែត នេវ។ គាត់នោះកើតនៅឃុំព្រាល -- ភូមិព្រាល ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ គឺជាភូមិដែលលោកស្រីរស់នៅសព្វថ្ងៃនេះ។ តើលោកស្រីមានស្គាល់ឈ្មោះ តាក ស៊ីម ហ្នឹងដែរឬទេ ដែលមានឈ្មោះត្រកូលដូចប្ដីលោកស្រីដែរនេះ?

**លោកស្រី តាក សាន់៖**

**ឆ៖** អត់ អត់ស្គាល់ទេខ្ញុំ។

**ស៖** បាទ លោកស្រីសំណួរចុងក្រោយ។ តើលោកស្រីមានស្គាល់បុគ្គលម្នាក់ដែលមកពីវៀតណាមខាងត្បូងនៅក្នុងឆ្នាំ១៩៧៦ ដែលមកនៅក្នុងភូមិខ្ពបត្របែក ដូចគ្នានឹងលោកស្រីដែរ ដែលគាត់ឈ្មោះ ពៅ បាទ ឈ្មោះ ពៅ នី បាទ លោកស្រីស្គាល់ឈ្មោះ ពៅ នី នេះដែរឬទេ?

**ឆ៖** នាងខ្ញុំអត់ស្គាល់ផង មិនដែលស្គាល់។

[១៤:០៦:២៥]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធានខ្ញុំសួរចប់ហើយ សូមអរគុណច្រើនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ខាងក្រុមមេធាវីការពារក្ដីមានអីសួរដែរទេ?

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំមានសំណួរតិចតួចទេលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនតូចទេ។ នៅពេលដែលលោកស្រីនិយាយអំពីស្ថានភាពម្ហូបអាហារ តើលោកអាច -- លោកស្រីអាចញែកឲ្យឃើញបានទេការហូបចុកនៅក្នុងឆ្នាំ១៩៧៦ តើស្ថានភាពម្ហូបអាហារវាយ៉ាងម៉េចដែរ ហើយមកចុង៧៧ វាមានស្ថានភាពបែបម៉េច ហើយ៧៨ ស្ថានភាពម្ហូបអាហារវាយ៉ាងម៉េចដែរ? សូមឲ្យលោកស្រីរៀបរាប់ក្នុងពេញមួយអំឡុងពេលនេះតែម្ដង។

**លោកស្រី តាក សាន់៖**

**ឆ៖** ចាស ហូបចុកហ្នឹងធម្មតា ស្លមានម្ហូបមានអី ប៉ុន្តែសម្លឆ្នាំងវាធំ តែប៉ុណ្ណឹង។

[១៤:០៧:៤៦]

**ស៖** តើលោកស្រីមានបន្លែ មានសាច់ មានដំឡូង មានផ្លែឈើអ្វីៗដែរទេ?

**ឆ៖** មានស្លបន្លែត្រកួន ដូចជាត្រប់ ននោងអីមាន ស្លឲ្យយើងហូបគ្រប់គ្នាហ្នឹង។

**ស៖** តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើស្ថានភាពចំណីអាហារវាដូចម្ដេចដែរនៅពេលដំបូងដែលលោកស្រីមកដល់ស្រុកត្រាំកក់? ហើយពេលក្រោយមកទៀត ហើយនិងរហូតទៅដល់ពេលចុងបញ្ចប់នៃការដួលរលំរបបខ្មែរក្រហម តើលោកស្រីអាចរៀបរាប់ពីស្ថានភាពចំណីអាហារក្នុងអំឡុងពេលនេះបានទេ?

**ឆ៖** ចាស រៀបរាប់ដឹងតែពីគេស្ល គេអីឲ្យហូបជាធម្មតាអីចឹងទៅ មានត្រី សាច់អីអីចឹងជាធម្មតាអីចឹងទៅ។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំយល់ហើយ សំណួររបស់ខ្ញុំគឺថា តើស្ថានភាពចំណីអាហារមានការភាពប្រសើរឡើងទេ? ឧទាហរណ៍ថាពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំហ្នឹង គឺចំណីអាហារហ្នឹងបានកើនឡើងទេ បានប្រសើរជាងមុនទេ?

**ឆ៖** ចាស យូរៗគេឲ្យហូបបាយម្ដង ចំណីចំណុកអីហ្នឹង ជួនកាលគេឲ្យបង្អែមម្ដងអីចឹងទៅ។

[១៤:០៩:៥៨]

**ស៖** ប្រហែលជាខ្ញុំសួរទៅវាមិនច្បាស់លាស់។ ខ្ញុំព្យាយាមចង់ដឹងថាតើៗស្ថានភាពចំណីអាហារហ្នឹងវាប្រសើរឡើងទេ? នៅពេលដំបូងអាចថាមិនមានចំណីអាហារគ្រប់គ្រាន់ ក្រោយមក ក៏មានចំណីអាហារគ្រប់គ្រាន់។ សូមលោកស្រីរៀបរាប់ពីពេលមួយទៅពេលមួយ ពីមួយឆ្នាំទៅមួយឆ្នាំហ្នឹង ស្ថានភាពហ្នឹងវាមានភាពប្រសើរឡើងទេ ចំណីអាហារហ្នឹង?

**ឆ៖** ចាស មុនដំបូង យើងហូបជាធម្មតាអីចឹងទៅ។ ដល់មកខែក្រោយៗទៀតអីចឹងទៅ វានៅមធ្យមដដែល។ ដល់ចូលមក១ខែ១ ២ខែទៀតទៅ គេឲ្យហូបបបរអីចឹងទៅ បាយទឹកអីហ្នឹង ឲ្យហូបបបរអីចឹង។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើវាត្រឹមត្រូវទេ បើខ្ញុំនិយាយថាពេលខ្លះចំណីអាហារហ្នឹងក៏វាតិច ពេលខ្លះក៏វាច្រើន ពេលខ្លះឆ្អាញ់ ពេលខ្លះមិនឆ្អាញ់ អីចឹងតើបើខ្ញុំនិយាយអីចឹងទៅ តើបានទេ?

**ផ៖** មិនដឹងថាឆ្ងាញ់ បើស្លទឹកច្រើន វាមានឆ្ងាញ់ខ្លះ មិនឆ្ងាញ់ខ្លះអ៊ីចឹងទៅ។ ថ្ងៃណាឆ្ងាញ់ អរអ៊ីចឹង ថ្ងៃណាមិនសូវឆ្ងាញ់ ក៏នៅតែស្ងៀមអ៊ីចឹងទៅ។

**ស៖** លោកស្រី តើលោកស្រីចាំទេ អ្នកដែលទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ចំណីអាហារហ្នឹង ផ្ដល់ចំណីអាហារ របបអាហារហ្នឹងស្មើៗគ្នាដែរឬទេ?

[១៤:១២:១៨]

**ផ៖** ខ្ញុំមើលទៅដូចជាមិនស្មើទេ ពួកមូលដ្ឋានអ៊ីចឹងទៅ គេហូបរាងក្រែលបន្តិចទៅ ហើយពួកខ្ញុំថ្មីអ៊ីចឹងទៅ ក៏រាងបន្ថយបន្តិចអ៊ីចឹងទៅ។

**ស៖** ចុះលោកស្រីអាចថាអ៊ីចឹងបាន ដោយសំអាងទៅលើអ្វីដែរ? លោកស្រីឃើញផ្ទាល់ភ្នែក?

**ផ៖** ខ្ញុំហូបហើយ ខ្ញុំឃើញ។

**ស៖** តើលោកស្រីអាចឃើញដោយផ្ទាល់ភ្នែក ថាលោកស្រីបានទទួលរបបអាហារតិចជាងអ្នកដទៃហ្នឹងដោយរបៀបម៉េច? លោកស្រីអាចមើលឃើញបានដោយរបៀបណា?

**ផ៖** បើខ្ញុំនៅហូបហ្នឹង ថាមិនឃើញ។ ខ្ញុំហូបនៅជាមួយ តុជាមួយតែគ្នាហ្នឹង។ ប៉ុន្តែគេក្រុម -- គេអង្គុយតុអ៊ីចឹងទៅ ហើយខ្ញុំអង្គុយតុខាងជិតហ្នឹងទៅ ឃើញ។

**ស៖** សូមលោកស្រីជម្រាបជូនអង្គជំនុំជម្រះថែមបន្តិចបានទេថា តើមានអ្នកដែលទទួលបានបាយច្រើន សម្លច្រើនជាងអ្នកដទៃ ឬក៏យ៉ាងដូចម្ដេចដែរ? សូមលោកស្រីរៀបរាប់ឲ្យបានរាងលម្អិតបន្តិចមើល។

[១៤:១៤:០៤]

**ផ៖** លម្អិតថាម៉េច បើច្រើនក៏វាមិនច្រើនប៉ុន្មានដែរ គេច្រើនលើយើងបន្តិចបន្តួចហ្នឹង ហើយគ្រាន់តែហូបបបរ ហូបអីហ្នឹងទៅ ជួនកាលហូបមិនឆ្អែតអ៊ីចឹងទៅ ក៏ខ្ញុំទឹកភ្នែកអ៊ីចឹងទៅ ដើរចេញទៅហូបហើយ ប៉ុន្តែមិនឲ្យគេឃើញ។

**ស៖** ចុះតើអ្នកដែលដាំស្ល ឬក៏ចែកបាយហ្នឹងអាច -- ធ្វើម៉េចគាត់អាចសម្គាល់បានថា អ្នកណាជាប្រជាជនថ្មី អ្នកណាជាប្រជាជនមូលដ្ឋាន? នៅក្នុងការរស់នៅជាក់ស្ដែងតែម្ដងហ្នឹង អ្នកដាំបាយ ឬក៏អ្នកចែកបាយហ្នឹង ធ្វើម៉េចគាត់ដឹងថា មានអ្នកណាជាអ្នកចាស់ អ្នកណាជាអ្នកថ្មី?

**ផ៖** គាត់ស្គាល់។ យាយតុញៗ ហ្នឹងគាត់ស្គាល់។ គាត់អ្នកដាំស្ល យាយតុញ នុ៎ង។

**ស៖** អ៊ីចឹងតើ យាយតុញ នុ៎ងគាត់ធ្វើយ៉ាងម៉េចទៅ គាត់ចែកយ៉ាងម៉េចទៅអ៊ីចឹង?

**ធ៖** ដួសចែកអ៊ីចឹងទៅ។ ដួសចែកដាក់លើតុអ៊ីចឹងទៅ ដល់ម៉ោងនាំគ្នាទៅហូបអ៊ីចឹងទៅ។

**ស៖** ខ្ញុំសូមបន្តចូលទៅប្រធានបទមួយផ្សេងទៀតលោកស្រី។ បើខ្ញុំមិនច្រឡំទេ លោកស្រីបានឆ្លើយថា ប្តីរបស់លោកស្រីបានបាត់ខ្លួននៅពេលមួយ។ តើលោកស្រីធ្លាប់ដែលបានឃើញផ្ទាល់ភ្នែកថាមានអ្វីកើតឡើងចំពោះប្តីលោកស្រីដែរទេ?

**ធ៖** ចាស ខ្ញុំមិនបានឃើញទេ ឲ្យប៉ុន្តែគេឲ្យប្តីខ្ញុំហ្នឹង -- នាងខ្ញុំហ្នឹងទៅដឹកស្រូវ អ៊ីចឹងថា យកទៅដាល់ -- យកមកដាល់អំបុកចែកគ្នាហូប។ ហើយដល់រួចទៅស្រាប់ប្តីខ្ញុំទៅបាត់អ៊ីចឹងទៅ បាត់មិនដឹងទៅអីណាមកអីណាអ៊ីចឹងទៅ មិនដឹងថាគេយកទៅអីណា បានជាខ្ញុំនឹកឃើញស្តាយប្តីខ្ញុំហ្នឹងណ៎ា។ មិនដឹងគេយកទៅសម្លាប់នៅកន្លែងណា។

[១៤:១៦:៥៥]

**ស៖** ខ្ញុំដឹងហើយ កាលណាសួរពីបញ្ហានេះ គឺថាលោកស្រីមានអារម្មណ៍មិនស្រួលទេ។ ប៉ុន្តែលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ លោកស្រីថា គេយកខ្លួនទៅបាត់ហ្នឹង តើលោកស្រីចង់មានន័យថាម៉េចហ្នឹងពាក្យថា "យកខ្លួនទៅបាត់ហ្នឹង"?

**ធ៖** មានន័យថាម៉េច មានតែប្តីខ្ញុំគេយកទៅណាបាត់ហ្នឹង មានតែយកទៅសម្លាប់ចោល បើមិនឃើញផង។ មកតែរទេះគោវិញ ទៅប៉ុន្មានរទេះបាត់ទាំងអស់។

**ស៖** តើលោកស្រីចាំទេ លោកស្រីមានបានឃើញដោយផ្ទាល់ភ្នែកទេ? មានឃើញអ្នកណាម្នាក់នាំខ្លួនលោកស្រីចាប់ -- នាំខ្លួនប្តីលោកស្រី ចាប់ខ្លួនប្តីលោកស្រីទៅកន្លែងណាមួយដែលលោកស្រីមិនស្គាល់ទីកន្លែងហ្នឹងៗ លោកស្រីបានឃើញអ៊ីចឹងទេ?

**ធ៖** ចាស នាងខ្ញុំអត់ឃើញទេ។ ឲ្យគាត់ហ្នឹងទៅដឹកស្រូវពូជហ្នឹង ស្រាប់តែទៅនឹងវាឃើញតែរទេះគោមកវិញ តែប្តីខ្ញុំអត់ឃើញ រទេះទៅប៉ុន្មានហ្នឹង អត់ឃើញមកទាំងអស់គ្នា បាត់ទាំងអស់ រហូតដល់ខ្ញុំបែកហ្នឹង ខ្ញុំរត់មកហ្នឹងបាត់រហូត។

**ស៖** ហើយនេះ គឺជាសំណួរចុងក្រោយរបស់ខ្ញុំហើយ ដើម្បីបញ្ជាក់ថា លោកស្រីមិនបានឃើញដោយផ្ទាល់ភ្នែកទេ នូវអ្វីដែលបានកើតឡើងចំពោះប្តីលោកស្រី ក្រៅតែពីថាថ្ងៃមួយគាត់បានចេញទៅហើយអត់បានឃើញត្រឡប់មកវិញ។ អ៊ីចឹងមែនទេ?

**ធ៖** ចាស ចេញទៅអត់ឃើញត្រឡប់មកវិញទេ។ ធ្លាប់តែនៅ ដល់តែពេលហូបបាយហូបទឹកអីមកមូលគ្នា ហូបសហករណ៍។

[១៤:១៩:00]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

មានសំណួរត្រូវសួរទេ ហើយបើត្រូវសួរ តើចំណាយពេលប្រហែលប៉ុន្មានទៅលោកមេធាវី?

**លោក គង់ សំអុន៖**

បាទ មានសំណួរលោកប្រធាន ប្រហែលជាអាច១៥នាទី។

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី ខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិក ធី.ភី.អូ មកកាន់កន្លែងដែលគាត់ថ្លែងរៀបរាប់អំពីទុក្ខសោកវេទនានៅចំពោះមុខអង្គជំនុំជម្រះនេះ នៅវេលាម៉ោងបីខ្វះម្ភៃនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២០ នាទី ដល់ម៉ោង ១៤:៤០ នាទី)*

[១៤:៤០:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរអ្នកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរតិចតួចទេដើម្បីសួរអ្នកស្រីបន្ថែម។ មុននេះបន្តិចនៅពេលដែលសហព្រះរាជអាជ្ញារងបានសួរអ្នកស្រីអំពីទីកន្លែងកំណើតរបស់អ្នកថាអ្នកស្រីកើតនៅ -- ជាខ្មែរកម្ពុជាក្រោម ឬកើតនៅកម្ពុជាក្រោម? អ្នកស្រីបានឆ្លើយថា អ្នកស្រីជាខ្មែរកម្ពុជាទេ មិនមែនជាខ្មែរក្រោមនោះទេ។ ខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីបានដឹងពីទម្រង់ឯកសារមួយដែលមានលេខ D22/3205 ដែលជាទម្រង់បែបបទព័ត៌មានរបស់ជនរងគ្រោះរបស់អ្នកស្រី ដែលបញ្ជាក់ថា អ្នកស្រីមានសញ្ជាតិជាខ្មែរកម្ពុជាក្រោម។ តើអ្នកស្រីបានដឹងពីចំណុចនេះដែរទេកន្លែងមក?

[១៤:៤២:២៨]

**លោកស្រី តាក សាន់៖**

**ឆ៖** ខ្មែរកម្ពុជាក្រោមមិនដឹង បើខ្ញុំនៅនុ៎ងហើយ មិនដឹងខ្មែរកម្ពុជាក្រោម ខ្ញុំហ្នឹងនៅកម្ពុជាក្រោម។

**ស៖** សំណួររបស់ខ្ញុំ ខ្ញុំសួរបញ្ជាក់ថា អ្នកស្រីមានសញ្ជាតិជាខ្មែរកម្ពុជាក្រោម ឬមួយក៏ជាខ្មែរ។ អ្នកស្រីអាចបញ្ជាក់សាឡើងវិញបានទេ?

**ឆ៖** ខ្ញុំជាខ្មែរកម្ពុជាលើ តែ--

**ស៖** បាទ សូមអរគុណ។ ប៉ុន្តែនៅក្នុងទម្រង់បែបបទរបស់អ្នកស្រីដែលតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ អ្នកស្រីនៅក្នុងទម្រង់ហ្នឹងគឺមានសរសេរថា សញ្ជាតិកម្ពុជាក្រោម ខ្មែរកម្ពុជាក្រោម។ ដូច្នេះហើយបានខ្ញុំសួរថា តើអ្នកស្រីដឹងថា ហេតុអីបានជាមានព័ត៌មានថាអ្នកស្រីមានសញ្ជាតិជាខ្មែរកម្ពុជាក្រោមនៅលើទម្រង់របស់អ្នកស្រីទេ?

**ឆ៖** ខ្ញុំឡើងទៅនៅឯលើ ខ្ញុំនៅឯក្រោមមែន តែដល់រួចទៅខ្ញុំឡើងនៅទៅឯលើ នៅស្រុកខ្មែរឯលើ។

**ស៖** បាទ អ្នកស្រីអ៊ីចេះ ខ្ញុំសួរអំពីទម្រង់ទេ ពីទម្រង់លេខឯកសារដូចខ្ញុំបានជម្រាបជូនអំមិញនេះ ពីព្រោះនៅក្នុងទម្រង់ហ្នឹងមានសរសេរដាក់ថា លោកស្រីហ្នឹងជាមានសញ្ជាតិខ្មែរកម្ពុជាក្រោម ហើយខ្ញុំចង់ដឹងពីចំណុចដែលមានបញ្ហាខ្វែងគ្នានេះ ពីព្រោះលោកស្រីមិនមែនជាអ្នកមានសញ្ជាតិខ្មែរ

កម្ពុជាក្រោមទេ។ ប៉ុន្តែក្នុងទម្រង់នោះបែរជាថាអ្នកស្រីមានសញ្ជាតិខ្មែរកម្ពុជាក្រោមទៅវិញ។ អ៊ីចឹង ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាមានព័ត៌មានបែបនេះ? អ្នកស្រីស្ដាប់បានទេ?

[១៤:៤៤:២៦]

**ផ៖** ចាស ស្ដាប់បាន តែខ្ញុំសញ្ជាតិនៅស្រុកក្រោម ដល់រួចទៅខ្ញុំមកនៅស្រុកលើ នៅរហូត អ៊ីចឹងទៅដល់សព្វថ្ងៃហ្នឹង។

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់បន្ថែមថា នៅពេលដែលលោកស្រីនៅប្រទេសវៀតណាមនោះ លោកស្រីមានសញ្ជាតិជាខ្មែរកម្ពុជាក្រោម ឬមួយយ៉ាងម៉េច? លោកស្រីអាចជម្រាបបានទេ?

**ផ៖** ដល់ខ្ញុំមកដល់នៅឯលើទៅ ខ្ញុំដាក់សញ្ជាតិឯលើទៅ សព្វថ្ងៃហ្នឹង តែខ្ញុំកើតៗនៅឯក្រោម នោះ។

**ស៖** បាទ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា អ្នកស្រីធ្លាប់ប្រើសញ្ជាតិជាខ្មែរកម្ពុជាក្រោមទេ កន្លងមក ក្នុងជីវិតរបស់អ្នកស្រី?

**ផ៖** ចាស ធ្លាប់ៗ ប្រើសញ្ជាតិវៀតណាម។

**ស៖** ជាសញ្ជាតិវៀតណាមមិនមែនសញ្ជាតិខ្មែរកម្ពុជាក្រោមទេ អ្នកស្រីអាចបញ្ជាក់ឲ្យច្បាស់ ម្ដងទៀតមើល?

**ផ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១៤:៤៦:០៣]

**ស៖** សូមអ្នកស្រីឆ្លើយ ព្រោះអម្បាញ់មិញអត់បានចូលក្នុងប្រព័ន្ធបកប្រែបាទ។

**ផ៖** ខ្ញុំសញ្ជាតិកម្ពុជាក្រោម។

**ស៖** បាទ បញ្ជាក់បន្ថែមនៅក្នុងអត្តសញ្ញាណប័ណ្ណរបស់អ្នកស្រីដែលមានលេខក្នុងឯកសារ D22/3205 ដដែលហ្នឹង។ លោកស្រីមានស្រុក -- នៅក្នុងអត្តសញ្ញាណប័ណ្ណនេះលោកស្រីមានស្រុក កំណើតនៅភូមិព្រាល ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ។ ចុះហេតុអីបានជាអ្នកស្រីដាក់ស្រុកកំណើត នៅក្នុងអត្តសញ្ញាណប័ណ្ណខុសពីការពិតរបស់អ្នកស្រីអ៊ីចឹង?

**ផ៖** ទេ អង្កាល់នោះ ម៉ែខ្ញុំគាត់ដាក់ហ្នឹង មិនដឹងគាត់ដាក់ឲ្យជាម៉េច ដាក់ -- គាត់ចុះសញ្ជាតិ អត្តសញ្ញាណប័ណ្ណហ្នឹង។ ខ្ញុំនៅតូចដែរ ខ្ញុំមិនសូវដឹងប្រវត្តិគាត់ធ្វើ។

**ស៖** បាទ អត្តសញ្ញាណប័ណ្ណដែលខ្ញុំនិយាយនេះ គឺជាអត្តសញ្ញាណប័ណ្ណថ្មីនៃព្រះរាជាណាចក្រ

កម្ពុជា។ បាទ ក្នុងនេះគឺមានចុះហត្ថលេខានៅក្នុងឆ្នាំ -- នៅថ្ងៃទី១៧ ខែ៧ ឆ្នាំ២០០២ ដូច្នេះ វាជារយៈពេល ១២ឆ្នាំកន្លងទៅ ដែលចេញដោយអាជ្ញាធររាជធានីភ្នំពេញ។ អ៊ីចឹង ខ្ញុំចង់សួរបញ្ជាក់ថា កាលនោះអ្នកស្រីនៅកុមារតូច ឬមួយអ្នកស្រីធំហើយ?

[១៤:៤៨:២២]

**ផ៖** ខ្ញុំធំហើយ ធំដឹងក្តីហើយ។

**ស៖** បាទ អ៊ីចឹងអ្នកណាអ្នកធ្វើអត្តសញ្ញាណប័ណ្ណហ្នឹង អ្នកស្រី ឬម្តាយអ្នកស្រីអ្នកធ្វើឲ្យ?

**ផ៖** ម្តាយខ្ញុំអ្នកធ្វើឲ្យ។

**ស៖** មិនមែនអ្នកស្រីទៅធ្វើខ្លួនទេ អ៊ីចឹង?

**ផ៖** ចាស ម៉ែខ្ញុំ។

**ស៖** ពីព្រោះទាក់ទងនឹងនីតិវិធីធ្វើអត្តសញ្ញាណប័ណ្ណនេះ វាត្រូវតែថតរូប ហើយអ្នកស្រីត្រូវទៅថតរូប ដាក់ពាក្យ មានការសម្ភាសអីទាំងអស់ មិនអាចធ្វើជំនួសបានទេ។

**ផ៖** ខ្ញុំទៅថតរូបទៅថតអីហ្នឹង ខ្ញុំទៅធ្វើ។ និយាយអំមិញខុស។ ខ្ញុំទៅធ្វើខ្លួនឯង សូមទោស។

**ស៖** បាទ អ៊ីចឹងត្រឡប់ទៅសំណួររបស់ខ្ញុំវិញ ខ្ញុំចង់ដឹងថា ហេតុអីបានជាមានភាពខុសគ្នាយ៉ាងដូច្នេះ? ពីព្រោះអ្នកស្រីបានឆ្លើយអម្បាញ់មិញថា អ្នកស្រីកើតនៅកម្ពុជាក្រោម នៅស្រុកវៀតណាម ហើយនៅក្នុងអត្តសញ្ញាណប័ណ្ណរបស់អ្នកស្រីថា កើតនៅប្រទេសកម្ពុជាវិញ នៅភូមិព្រាល ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ។ អ្នកស្រីអាចបញ្ជាក់បានទេ?

[១៤:៥០:០៧]

**ផ៖** អ្ហឺ! ខ្ញុំកើតនៅភូមិព្រាល ហើយកើតនៅស្រុកយួន ដូចកើតនៅ -- ខ្ញុំកើតនៅភូមិព្រាល ស្រុកគីរីវង់ ខេត្តតាកែវ កាលនោះ។

**ស៖** បាទ អ៊ីចឹងអ្នកស្រីបដិសេធថា អ្នកស្រីមិនមែនកើតនៅប្រទេសវៀតណាមទេ អ៊ីចឹងមែនទេ?

**ផ៖** ចាស ខ្ញុំកើតនៅស្រុកគីរីវង់ ខេត្តតាកែវ ខ្ញុំមិនបាននៅកើតនៅឯស្រុកក្រោមទេ ខ្ញុំសូមទោស និយាយកាលពីពេលមុនខុស ឥឡូវខ្ញុំសូមទោស ខុស។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីចាំបានទេថា អ្នកណាជាអ្នករៀបចំទម្រង់បែបបទរបស់អ្នកស្រីហ្នឹង?

**ផ៖** ទម្រង់បែបបទយ៉ាងអាម៉េចទេ មិនដឹងផង។

**ស៖** ទម្រង់បែបបទព័ត៌មានរបស់ជនរងគ្រោះដែលមានឯកសារ D22/3205 អ្នកស្រីចាំទេ?

**ផ៖** ចាំ គេធ្វើឲ្យខ្ញុំនៅជិតខាងហ្នឹងគេធ្វើឲ្យ។

**ស៖** អ្នកស្រីស្គាល់ឈ្មោះគេទេ?

**ផ៖** ស្គាល់។

**ស៖** ឈ្មោះអី?

**ផ៖** ឈ្មោះ ញ៉ាន់។

[១៤:៥២:១២]

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារដែលខ្ញុំលើកអម្បាញ់មិញ ទម្រង់បែបបទរបស់អ្នកស្រីហ្នឹង នៅចំណុចកន្លែងចុះហត្ថលេខាជាសាក្សី មានឈ្មោះ ចៅ នី។ តើលោកស្រីស្គាល់ឈ្មោះ ចៅ នី ហ្នឹងទេ?

**ផ៖** ចាស នាងខ្ញុំអត់ស្គាល់ផង ចៅ នី ហ្នឹង។ ខ្ញុំមិនបានដឹងផង។

**ស៖** បាទ ខ្ញុំចង់សូមជម្រាបលោកស្រីថា នៅក្នុងទម្រង់របស់លោកស្រីហ្នឹង ឈ្មោះ ចៅ នី ហ្នឹងបានចុះហត្ថលេខា ក្នុងនាមជាសាក្សីក្នុងការបំពេញទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់អ្នកស្រី។ អ៊ីចឹងអ្នកស្រីអត់ដែលបានជួប ចៅ នី ហ្នឹងដោយផ្ទាល់ទេ ឬមួយក៏អ្នកស្រីភ្លេច? អ្នកស្រីអាចឆ្លើយបានទេ?

**ផ៖** ខ្ញុំ នាងខ្ញុំមិនដែលស្គាល់ ចៅ នី ហ្នឹងផង មិនដឹងមុខអាម៉េចអីអាម៉េចផង នាងខ្ញុំអត់ស្គាល់។ ខ្ញុំក៏មិនដែលឃើញ។

**ស៖** បាទ ខ្ញុំសូមជម្រាបជូនលោកស្រីថា ចៅ នី ហ្នឹងគាត់ធ្លាប់មកធ្វើ ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះរួចហើយនៅក្នុងសំណុំរឿង០០២/០១ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។ អ្នកស្រីអាចមានការចងចាំទាក់ទងទៅនឹងព័ត៌មានរបស់លោក ចៅ នី នេះដែរឬទេ?

**ផ៖** ខ្ញុំមិនស្គាល់ផង ហើយម៉េចបានខ្ញុំទាក់ទងម៉េចបានទៅ បើខ្ញុំមិនដែលស្គាល់។

[១៤:៥៤:១៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ដូចគួរតែផ្តោតទៅលើការថ្លែងទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្តឹង

រដ្ឋប្បវេណីទៅបានហើយ ដូចជាឆ្ងាយពេកពីអ្វីដែលយើងកំពុងតែធ្វើដំណើរការសវនាការនាពេលនេះ។

**សួរដោយលោក គង់ សំអុន**

**ស៖** បាទ ខ្ញុំតទៅប្រធានបទមួយទៀត ទាក់ទងទៅនឹងសំណង។ នៅក្នុងឯកសារ D25/3205 ក្នុងទំព័រចុងក្រោយ ខ្ញុំសូមអានជូន ខ្ញុំជឿថានៅក្នុងភាសាអង់គ្លេសដែលមានតែមួយទំព័រនោះគឺនៅផ្នែកខាងចុងគេបំផុត។ សូមដកស្រង់៖ “ក្នុងពាក្យបណ្តឹង ខ្ញុំសូមទាមទារសំណងផ្លូវចិត្ត និងទ្រព្យសម្បត្តិដែលបានបាត់បង់ក្នុងរបបខ្មែរក្រហមដូចជា ផ្ទះ គោ ក្របី។ល។” ខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីនៅប្រកាន់ជំហរក្នុងការទាមទារទៅលើសំណងជាលក្ខណៈឯកជនបែបនេះទៀតទេ ក្នុងពេលឥឡូវនេះ?

**លោកស្រី តាក សាន់៖**

**ឆ៖** ទាមទារអី បើឲ្យក៏យកទៅ បើមិនឲ្យក៏មិនដឹងធ្វើម៉េចដែរ បើបាត់បង់ទៅហើយ មិនដឹងទាមទារថាម៉េចទេ។

[១៤:៥៦:១២]

**ស៖** អ្នកស្រីអាចបញ្ជាក់ឲ្យបានច្បាស់ជាងនេះបានទេ ថាអ្នកស្រីទាមទារ ឬក៏បោះបង់ចោលជំហរថាឈប់ទាមទារ?

**ឆ៖** ខ្ញុំមិនចង់ទាមទារអីទេ ចង់ទាមទារឲ្យបានប្តីខ្ញុំ ខ្ញុំស្តាយប្តីខ្ញុំពេក កូនប្តី។

**ស៖** បាទ អ្នកស្រីមិនចង់ឆ្លើយ ឬមួយយ៉ាងម៉េចក្នុងសំណួរនេះ? បើអ្នកស្រីយល់ថាមិនចង់ឆ្លើយ ខ្ញុំសូមបញ្ចប់ត្រឹមនេះ។

**ឆ៖** មិនដឹងទាមទារថាម៉េច បើបាត់ទៅហើយ។

**ស៖** មូលហេតុដែលខ្ញុំសួរនេះ ដោយសារនៅក្នុងទម្រង់បែបបទរបស់អ្នកស្រីហ្នឹងបានបញ្ជាក់ដូចបានខ្ញុំអានជូនអំមិញហ្នឹង អ្នកស្រីទាមទារផ្ទះ គោ ក្របី ជាដើម ណា៎ ដែលបានបាត់បង់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងសំណួររបស់ខ្ញុំសួរថា អ្នកស្រីនៅប្រកាន់ជំហរទាមទារបែបនេះ ឬមួយក៏អ្នកស្រីបញ្ឈប់ការទាមទារ?

**ឆ៖** មិនដឹងទាមទារពីអីទេ បើស្លាប់បាត់បង់ទៅហើយមិនដឹងទាមទារថាម៉េចទេ ខ្ញុំមិនចេះ។

[១៤:៥៧:៥៥]

**លោក គង់ សំអុន៖**

បាទ អរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រី គាក សាន់។ ការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកស្រីអះអាងថា លោកស្រីបានទទួលរងក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យបានដល់ទីបញ្ចប់ហើយ។ ហើយលោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី គាក សាន់ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ដោយឡែកលោកស្រីបុគ្គលិករបស់អង្គការ ធី.ភី.អូ អង្គុយនៅទីនោះដដែលចុះ រង់ចាំធ្វើសវនាការបន្តស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-985។ ហើយមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-985 មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៥:០០:១៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោក អៀម យេន៖**

**ឆ៖** ចាស ខ្ញុំឈ្មោះ អៀម យេន។

**ស៖** អរគុណលោកស្រី អៀម យេន។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំដែរឬទេ?

**ឆ៖** ចាស ខ្ញុំកើតនៅថ្ងៃទី៨ ខែ៩ ឆ្នាំ១៩៧០។ បើតាមជាអាយុខ្ញុំពិត ឆ្នាំ១៩៦៨។

**ស៖** អរគុណ ហើយសព្វថ្ងៃនេះ តើលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ចាស សព្វថ្ងៃនេះ ខ្ញុំរស់នៅភូមិទួលពង្រ ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ។

[១៥:០១:១៨]

**ស៖** អរគុណ ហើយលោកស្រីប្រកបមុខរកស៊ីធ្វើអ្វីដែរ?

**ឆ៖** ចាស ខ្ញុំមុខរបរស៊ីសព្វថ្ងៃនេះ ធ្វើស្រែ។

**ស៖** តើឪពុកបង្កើតរបស់លោកស្រី គាត់ឈ្មោះអី?

**ឆ៖** ចាស ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ម៉ម ប្រុស។

**ស៖** ចុះម្ដាយបង្កើតរបស់លោកស្រី គាត់ឈ្មោះអី?

**ឆ៖** ម្ដាយបង្កើតរបស់ខ្ញុំឈ្មោះ អៀម -- អំ! អួប យន។

**ស៖** ចុះប្ដីរបស់លោកស្រី គាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ចាស ប្ដីរបស់នាងខ្ញុំឈ្មោះ សំ អុន ហើយនាងខ្ញុំមានកូនប្រាំពីរនាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរ ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ពាក់ព័ន្ធជាមួយនឹងស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលគាត់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សូមអញ្ជើញ!

[១៥:០២:៣៩]

**លោក ឡោ ជុនធី៖**

បាទ អរគុណ។ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ហើយខ្ញុំបាទនៅពេលនេះ សូមជម្រាបសួរលោកស្រី អៀម យេន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សំណួរទី១ ដែលខ្ញុំចង់ជម្រាបសួរ ថាតើលោកស្រី អៀម យេន កាលពីឆ្នាំ១៩៧៥ នោះគេបានបញ្ជូនលោកស្រីពីខេត្តណាទៅខេត្តណា? ឬមួយពីភូមិណាទៅភូមិណាដែរ?

**លោកស្រី អៀម យេន៖**

**ឆ៖** ចាស ឆ្នាំ១៩៧៥ ខ្ញុំបានមកនៅភូមិ -- គេបានបញ្ជូនខ្ញុំមកពីភូមិទួលពង្រ ឃុំសោម ស្រុកគីរីវង់ហ្នឹង មកនៅភូមិត្រពាំងធំខាងជើង ស្រុក -- ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** បាទ អរគុណ។ ថាតើនៅក្នុងឆ្នាំ១៩៧៦ តើលោកស្រីត្រូវបានគេបញ្ជូនទៅក្នុង ឲ្យទៅធ្វើ

ការនៅក្នុងកងអ្វីដែរបាទ?

[១៥:០៤:១៩]

**ឆ៖** ចាស កាលពីឆ្នាំ១៩៧៦ គេបានបញ្ជូនខ្ញុំឲ្យទៅនៅភូមិទួលគ្រួសមួយ ហើយពេលនោះ គេបានបំបែកខ្ញុំចេញពីឪពុកម្ដាយឲ្យទៅធ្វើការ។ ទៅធ្វើការអ៊ីចឹង គេឲ្យខ្ញុំហ្នឹង ទៅកាប់ដី ទំនប់ទួលគ្រួសហ្នឹង។ ឧបមាថាអ៊ីចឹង គេចែកចេញជាប្រាំក្រុម ក្នុងមួយក្រុមហ្នឹងវាមាន១០នាក់ មួយកងមាន៥០នាក់អ៊ីចឹង គេឲ្យខ្ញុំទៅជីក។ ជីកអ៊ីចឹង មនុស្សក្មេងហ្នឹង ឧបមាថា ១០នាក់ហ្នឹង ធ្វើម៉េចជីកឲ្យបាន១០ម៉ែត្រគូប បើសិនជាមនុស្សចាស់វិញ ១០នាក់១៥ម៉ែត្រគូប។ ហើយគេឲ្យនាងខ្ញុំហ្នឹងទៅជីកៗ បើសិនជាបានអាហ្នឹងអត់អីទេត្រូវផែនការ បើសិនជាមិនបាននឹងធ្វើបាបនាងខ្ញុំហ្នឹងបង្អត់អាហារ វាយនាងខ្ញុំ។ ដល់ពេលនោះ នាងខ្ញុំហ្នឹងក៏ទ្រាំធ្វើអ៊ីចឹង ធ្វើដូចថា យូរទៅធ្វើមិនបាននាងខ្ញុំហ្នឹងក៏រត់មករកឪពុកម្ដាយៗអ៊ីចឹងនៅឆ្នាំដល់ពេលចុងឆ្នាំ ដល់ឆ្នាំ១៩៧៧ គេឲ្យនាងខ្ញុំហ្នឹងដើររើសអាចម៍គោ រើសអាចម៍ជ្រូកអ៊ីចឹង។ នាងខ្ញុំក៏ធ្វើមិនបានៗ ព្រោះអីពេលនោះ ខ្ញុំនៅក្មេងអាយុទើបតែតិចដែរហ្នឹង ខ្ញុំក៏មានការនឹកម៉ែនឹកឪ អ៊ីចឹងខ្ញុំក៏លួចរត់មកផ្ទះ។ ខ្ញុំលួចរត់មកអ៊ីចឹង គេតាមមកចាប់ខ្ញុំយកទៅ យកទៅគេវ៉ៃខ្ញុំ ហើយគេជីកដីកប់ ជីកកប់ខ្ញុំរយៈពេលប្រហែលជា២ម៉ោង ឬ៣ម៉ោងអ៊ីចឹង បានហើយគេព្រមានខ្ញុំទៀតថា "នាងឯងឈប់ធ្វើអ៊ីចឹងទៀតណា៎ តែធ្វើអ៊ីចឹងទៀតថ្ងៃក្រោយគេសម្លាប់ហើយ"។ ដល់ពេលអ៊ីចឹង នាងខ្ញុំក៏ស្រេកទឹក បាយក៏ឃ្លាន ហើយអារាងកាយខ្ញុំហ្នឹងគេកប់ ខ្ញុំដកដង្ហើមសឹងមិនចង់រួច ខ្ញុំសឹងតែស្លាប់មួយភ្លែតហ្នឹង។ ខ្ញុំស្រែកហៅម៉ែៗក៏មិនឃើញមកជួយ ឪៗក៏មិនឃើញមកជួយ ដល់អ៊ីចឹងខ្ញុំថា ខ្ញុំមានតែសេចក្ដី -- គ្មានសេចក្ដីសុខទេ មានតែសេចក្ដីទុក្ខប៉ុណ្ណឹង។

[១៥:០៦:៤៧]

ដល់រួចពេលនោះទៅ ខ្ញុំនឹងក៏គេយកមកកងវិញៗ គេឲ្យខ្ញុំហ្នឹងធ្វើការវិញដដែលពេលក្រោយពីគេជីកខ្ញុំកប់គេលែងឲ្យធ្វើការដែរ ប៉ុន្តែគេព្រមានខ្ញុំអ៊ីចឹង ខ្ញុំក៏ខ្លាចៗអ៊ីចឹង។ ដល់ឆ្នាំ១៩៧៨ ហ្នឹងគេឲ្យខ្ញុំធ្វើការទៀតហើយ ធ្វើអ៊ីចឹងដដែល ឲ្យកាប់អាទន្រ្ទានខែត្រហ្នឹងយកមកលាយជាមួយអាលាមកយើងអាទឹក ហើយនិងទឹកនោមយើងហ្នឹងលាយធ្វើជីជាមួយដីដំបូក ដល់ពេលលាយអ៊ីចឹងគេដាក់ខាបពីរក្នុងផ្ទះហ្នឹង។ ផ្ទះមួយរាងទ្រុឌទ្រោមដែរហើយ គេឲ្យដាក់លាមកទឹកមួយចំហៀង លាមកគោកមួយចំហៀង។ គេឲ្យសែងចុះក្នុងមួយក្រុមអ៊ីចឹង ចំនួនជា១០នាក់អ៊ីចឹងគេឲ្យសែងមួយពាងអ៊ីចឹងបួនៗនាក់។ ដល់ខ្ញុំសែងចុះមកអ៊ីចឹង ដល់រួចខ្ញុំរាល់ថ្ងៃហ្នឹង ខ្ញុំធុញថប់ពេក ខ្ញុំធ្វើមិនបានខ្ញុំរត់កងទៀតហ្នឹង ខ្ញុំរត់កង

វត់ជាពីរលើកបីលើក។ គេតាមចាប់ខ្ញុំមកធ្វើបាបអ៊ីចឹង។ ដល់រួចទៅខ្ញុំហ្នឹង គេឲ្យទៅរើសអាចម៍គោទៀតហើយ ទៅតាមសហករណ៍គេ គេហៅថា សហករណ៍។ អាចម៍ជ្រូក ខ្ញុំអង្គុយចាំអាជ្រូកមួយជុះអាចម៍យូរពេក ខ្ញុំឃើញពូមួយនោះ គាត់មកអ៊ីចឹង គាត់បររទេះមកៗអ៊ីចឹង គាត់ដឹកដំឡូងមក។ ខ្ញុំក៏ឃ្លានពេកខ្ញុំអង្គុយចាំហើយ ខ្ញុំក៏លួចបាយជ្រូកគេនុ៎ងហូបបន្តិចទៅ។ ដល់អ៊ីចឹងខ្ញុំអង្គុយចាំមើលយូរពេក ខ្ញុំក៏លូកដៃហ្នឹងរត់ទៅតាមរទេះគោពូនុ៎ង ក៏លួចហូតដំឡូងនុ៎ងបានជាប្រហែលជាបីគល់ទេ។ ដល់អ៊ីចឹងគេ ក្រឡេកមកអ៊ីចឹងគេឃើញខ្ញុំទាន់ ដល់ឃើញខ្ញុំទាន់ ក៏លើកខ្ញុំហ្នឹងបោះទៅលើរទេះគោនុ៎ង។ ដល់បោះទៅអ៊ីចឹងហើយខ្ញុំហ្នឹងក៏ទៅដើរចុះមកៗអ៊ីចឹង គេនុ៎ងក៏គេបោះខ្ញុំទៅលើហ្នឹងទៀត លែងឲ្យខ្ញុំរើៗ ដល់ទៅដល់ថា ការដ្ឋានៗនុ៎ង អាហ្នឹងនៅទំនប់តាគុយ ខ្ញុំដឹងថា តាគុយ អ៊ីចឹងព្រោះអីខ្ញុំមិនដឹងឆ្នាំអា ដូចថា ភូមិឃុំអីទេពេលនោះ។ អ៊ីចឹងគេសួរថា “នាងឯងនៅកងណា?” អ៊ីចឹងណ៎ា។ ខ្ញុំក៏ថា “ខ្ញុំនៅទំនប់តាគុយ”។ ខ្ញុំនៅទំនប់តាគុយ អ៊ីចឹងគេហ្នឹងក៏ប្រាប់ប្រធានក្រុមខ្ញុំហ្នឹងមក ឲ្យមកយកៗខ្ញុំហ្នឹងមានប្រធានកងមួយ ប្រធានក្រុមពីរ។ ដល់មកយកខ្ញុំទៅៗ ខ្ញុំស្មានតែយកខ្ញុំអត់ឲ្យធ្វើអី ពេលយកខ្ញុំទៅអ៊ីចឹងស្រាប់តែហៅខ្ញុំហ្នឹងឡើងលើផ្ទះៗក៏គេចាប់ផ្ដើមចងខ្ញុំហើយ ប៉ុន្ដែទន្ទឹមចងខ្ញុំហ្នឹង ខ្ញុំរើសអាចម៍ជ្រូកវាមានបីនាក់ ប៉ុន្ដែពីរនាក់នោះ ឈ្មោះគេ មីណាត អ៊ីចឹងទៅគេអត់បានលួចទេ។ គេនៅចាំរើសអាចម៍ជ្រូក ដល់ពេលខ្ញុំលួចអ៊ីចឹងមកគេចាប់មកតែម្ដងឯងហ្នឹង។ ដល់គេចងហើយគេហៅពីរនាក់នោះមកទៀត ថាដំណើរទៅជាមួយគ្នា។ ដល់គេចងខ្ញុំហ្នឹងក៏គេចាប់ផ្ដើមចង គេចងជើងខ្ញុំហ្នឹងជាប់គ្នាហើយដល់ដៃខ្ញុំហ្នឹងគេចងទៅក្រោយ ហើយខ្ញុំមានសក់ក្បាលបន្ដិច អាបង្អួច អាចម្រឹងបង្អួចហ្នឹងចងសក់ខ្ញុំអ៊ីចឹងជាប់អាចម្រឹងបង្អួចនោះមួយថ្ងៃ។ ដល់ពេលអ៊ីចឹង ខ្ញុំស្រេកទឹក ស្រេកទឹកពេកខ្ញុំថា ចុះអង្គាល់ហ្នឹងខ្ញុំហៅមិត្តបង “មិត្តបងអ្ហា! ខ្ញុំសូមទឹកហូបបន្តិចមក” ក៏គេធ្វើមិនឮ ហើយហៅក៏ហៅ គេបង្អត់អាហារខ្ញុំហ្នឹង អត់មានឲ្យអីហូបឯណា។ ខ្ញុំហៅអ៊ីចឹង ទៅម្ដងមិនឮពីរដងមិនឮ ដល់ប្រហែលបីដងអ៊ីចឹង ខ្ញុំថា “មិត្តបង ខ្ញុំសុំទឹកបន្តិចមក” ដល់ខ្ញុំថា សុំហូប គេយកទឹកហ្នឹងមកបញ្ច្រកខ្ញុំអ៊ីចឹងណ៎ា បញ្ច្រកខ្ញុំឈ្លក់សឹងដាច់ខ្យល់ស្លាប់មួយភ្លែតហ្នឹង។ បញ្ច្រកទឹកខ្ញុំហើយអីហើយអ៊ីចឹង ក៏គេចងតទៅទៀត ដល់ពេលនេះប្រធានកងហ្នឹងគេឲ្យប្រធានក្រុមហ្នឹង គេយករំពាត់មួយហ្នឹង មិនឫស្សីទេ ខ្ញុំមើលរំពាត់ហ្នឹងខ្ញុំមើលវាងដូចថាមិនឃើញដែរ វាងស្ទុងៗ ព្រោះអីគេចងខ្ញុំទៅអ៊ីចឹងហើយហ្នឹង ខ្ញុំមើលទៅខ្ញុំថាដូចពីរំពុងឈើមួយប្រហែលជាប៉ុនមេដៃ គេយកមកដល់អ៊ីចឹងវ៉ៃពោះខ្ញុំខ្វាច់ៗ ហើយវ៉ៃជើងខ្ញុំ ហើយព្រមានថា “ថ្ងៃក្រោយឈប់ដើរលួចអ៊ីចឹងទៀត” ហើយខ្ញុំហ្នឹងក៏ឆ្លើយថា “ចាស”។ អ៊ីចឹងទៅជិតដល់ពេលយប់

ពេលក្រុមកុមារមកពីធ្វើការវិញអ៊ីចឹង ខ្ញុំហ្នឹងក៏ជំនុំគ្នាបីនាក់ថា "តោះឥឡូវយើងសុំគេបត់ជើងធំតោះ!" ដល់សុំអ៊ីចឹងពីរនាក់នោះគេអត់ប៉ានសុំទេ ខ្ញុំក៏សុំថា "មិត្តបងអើយមិត្តបង! ខ្ញុំសូមបត់ជើងធំបន្តិច ខ្ញុំរាកបត់ជើងធំណាស់" ថាអ៊ីចឹង ពីរដងក៏គេស្រាយទៅ។ ហើយខ្ញុំក៏បានជំនុំគ្នាទៀត ខ្ញុំថា "អ្ហ៎! យើងគេចងជាប់អ៊ីចឹង យើងមកបត់ជើងធំ យើងធ្វើសំងំឲ្យបានយូរបន្តិចទៅ ឲ្យដៃយើងបាត់ហើម មើលដៃខ្ញុំនេះហើមមាំណាស់" ខ្ញុំនិយាយមិនទាន់រួចពីមាត់ហ្នឹងផង ស្រាប់តែគេហៅខ្ញុំហ្នឹងឡើងទៅទៀត ឡើងទៅចងលើផ្ទះហ្នឹងទៀត ចងទាំងបីអ៊ីចឹងទៀត ដូចដើមដដែល។

[១៥:១១:៥២]

ដល់តែពេលយប់ ពេលថាយប់ពេលកងកុមារមកពីធ្វើការក្រុមជាមួយគ្នា ពួកខ្ញុំហ្នឹងអីហ្នឹង មកពីធ្វើការវិញអ៊ីចឹង គេក៏មើលឃើញពួកខ្ញុំបីហ្នឹងចងនៅលើផ្ទះដែរ។ ដល់អ៊ីចឹងយប់ឡើងគេស្រាយពួកខ្ញុំ ស្រាយពួកខ្ញុំស្មានតែស្រាយឲ្យនេះរួចថាធម្មតាអត់មានអី ស្រាយហើយអ៊ីចឹងក៏គេហៅពួកខ្ញុំហ្នឹងចូលអង្គប្រជុំ។ អង្គប្រជុំមានកុមារដូចគ្នាអ៊ីចឹង គេថា ពេលយប់ហ្នឹងប្រជុំ ៗកុមារគ្នាឯងអ្នកគេធ្វើការ ដូចថាគេធ្វើការសកម្មអ៊ីចឹង គេមកថា"ខ្ញុំសូមទិតៀន ហើយស្វ័យទិតៀនអ្នកណាដែលបានធ្វើខុសត្រូវទទួលកំហុស" ហើយខ្ញុំហ្នឹងដឹងខ្លួន ក៏ខ្ញុំឡើង ខ្ញុំថា "សូមទទួលកំហុស ថ្ងៃមុខថ្ងៃក្រោយខ្ញុំលែងធ្វើអ៊ីចឹងទៀតហើយ ខ្ញុំក៏បាននិយាយអ៊ីចឹង"។ ដល់ពេលអ៊ីចឹងទៅ ក៏គេឲ្យខ្ញុំហ្នឹងធ្វើការធម្មតាអ៊ីចឹងវិញទៅ។ ខ្ញុំធ្លាប់តែមានថា ថ្ងៃ១០ ថ្ងៃ២០ ពេលនោះពេលជម្លៀសចេញអ៊ីចឹងឲ្យកុមារនៅផ្សេង គេតែងតែមានថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ ដល់តែពេលយូរទៅកាត់បន្ថយរឿងទាំងម្ហូបអាហារហ្នឹងអត់មាន ហើយខ្ញុំហ្នឹងក៏ប្រើធ្វើការហួសកម្លាំង ហើយថ្ងៃ១០ ថ្ងៃ២០ហ្នឹងក៏គ្មានដែរ ខ្ញុំចេះតែរត់ចេះតែអីអ៊ីចឹងទៅ។ ដល់ពេលនេះទៅឲ្យខ្ញុំធ្វើការអ៊ីចឹងដដែល។

**ស៖** សូម១១ អម្បាញ់មិញលោកស្រីបានលើកឡើងថា កន្លងទៅគេឲ្យមកជួបម្ដាយ មានថ្ងៃ១០ មានថ្ងៃ២០។ ចុះហេតុអីបើគេឲ្យជួបថ្ងៃ១០ ថ្ងៃ២០ហើយ ម៉េចបានរត់ទៅរកជួបម្ដាយទៀតបាទ?

**ឆ៖** ចាស មុនឲ្យខ្ញុំថា មានថ្ងៃ១០ ថ្ងៃ២០ហ្នឹង អ៊ីចឹងបានខ្ញុំចង់និយាយថា ពេលនុំងខ្ញុំត្រូវមានថ្ងៃ១០ ថ្ងៃ២០។ ដល់តែពេលកាត់បន្ថយពីថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ហ្នឹងទៅ ខ្ញុំមិនរត់គេចចេញ រត់ទៅរកម៉ែរកឪ ព្រោះអីខ្ញុំនៅតូច ខ្ញុំត្រូវការឪពុកម្ដាយជាការថ្នាក់ថ្នមខ្ញុំ។ អ៊ីចឹងហើយខ្ញុំត្រូវរត់ទៅរកគាត់ បើកាត់បន្ថយខ្ញុំតាំងពីជួបម៉ែឪ តាំងពីហូបចុក។

[១៥:១៤:៣៨]

**ស៖** បាទ ចុះក្នុងជំនាន់ហ្នឹងគេឲ្យលោកស្រីទៅក្នុងកងចល័ត តើនៅក្នុងកងចល័តហ្នឹងមានការបង្រៀនអក្សរមានអីដែរបាទ?

**ឆ៖** ចាស ជំនាន់នោះអត់មានការបង្រៀនសូត្រអីទេ មានតែការធ្វើពលកម្ម យប់ផ្លាស់កង ថ្ងៃធ្វើការ។

**ស៖** ចុះពាក់ព័ន្ធនឹងរបបអាហារ ព្រោះមាន -- លោកស្រីបានលើកឡើងថា ពេលទៅរើសអាចម៍គោ ពេលទៅរើសអាចម៍ជ្រូកហ្នឹង ឃើញដំឡូងគេទៅលួចដំឡូងគេ។ ចុះរបបអាហារយ៉ាងដូចម្ដេចដែរបាទ?

**ឆ៖** ចាស ពេលខ្ញុំថា ទៅលួចដំឡូងគេ ពេលរើសអាចម៍ជ្រូកនោះ មកពីខ្ញុំហូបចុកអត់មានគ្រប់គ្រាន់ ខ្ញុំហេវ ខ្ញុំឃ្លាន បានខ្ញុំដាច់ចិត្តទៅលួចដំឡូងគេ។

[១៥:១៦:០៨]

**ស៖** អម្បាញ់មិញលោកស្រីបានលើកឡើងថា ពេលដែលលួចដំឡូងគេ ត្រូវគេចាប់ធ្វើទារុណកម្ម។ មានន័យថា តើគេធ្វើទារុណកម្មដោយចងដៃចងជើងអម្បាញ់មិញដែលលោកស្រីបានលើកឡើងហ្នឹង ឬមួយយ៉ាងម៉េច?

**ឆ៖** ចាស ពេលខ្ញុំនិយាយថា ខ្ញុំ -- ធ្វើទារុណកម្មលើខ្ញុំនោះ ពេលហ្នឹងដូចខ្ញុំបាននិយាយថា អ៊ីចឹង ខ្ញុំ -- ព្រោះខ្ញុំឃ្លាន ខ្ញុំទៅលួចដំឡូងគេបានគេចាប់ខ្ញុំបោះលើរទេះ។ លើរទេះមក ខ្ញុំរើរួចៗ គេចាប់ខ្ញុំបោះទៅទៀតៗហើយ គេក៏ឃាំងមិនឲ្យខ្ញុំចុះពីលើរទេះគោនោះដែរ ទៅដល់កន្លែងសហករណ៍ហ្នឹង បានគេហៅប្រធានកង ប្រធានក្រុមមកយកខ្ញុំទៅចងវាយធ្វើបាបខ្ញុំពេលនោះ។

**ស៖** ចុះតើការបែកលំនៅពីឪពុកម្ដាយហ្នឹង យើងបែកតាំងពីក្នុងឆ្នាំ១៩៧៦ មក ឬមួយក្រោយមកទៀត? ហើយការបែកហ្នឹង បែករហូតក្នុង -- រហូតទៅដល់ឆ្នាំ១៩៧៩ តែម្ដង ឬមួយយ៉ាងម៉េច?

**ឆ៖** ចាស ការបែកពីឪពុកម្ដាយហ្នឹង ខ្ញុំបែកតាំងពីឆ្នាំ១៩៧៦ហ្នឹង ប៉ុន្តែគេឲ្យមានជួបឪពុកម្ដាយក្នុងមួយខែបីដង។ ដល់តែពេលយូរទៅគេកាត់បន្ថយនៅត្រឹមតែមួយខែម្ដងទេ មិនដាច់រហូតទេ ប៉ុន្តែខ្ញុំត្រូវការឪពុកម្ដាយខ្ញុំ ការថ្នាក់ថ្នម ខ្ញុំនឹករឭកគាត់ពេក។

**ស៖** ចុះនៅពេលដែលលោកស្រីបានថា នឹករឭកពេក ពេលនោះមានសុំគេទៅជួបឪពុកម្ដាយទេបាទ?

[១៥:១៨:៣៥]

**ឆ៖** ចាស ពេលនោះ ខ្ញុំដូចថា នឹករឭកពេក ចង់ខ្ញុំសុំគេទៅជួបឪពុកម្តាយ ក៏គេមិនឲ្យទៅដែរ ព្រោះអីគេមានផែនការគេថា ថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ បើអ៊ីចឹងគេកាត់បន្ថយហើយ ខ្ញុំសូមទៅក៏គេមិនឲ្យខ្ញុំទៅដែរ ព្រោះខ្ញុំសុំម្តង ពីរដងអ៊ីចឹងក៏គេមិនឲ្យទៅដែរ គេថាឲ្យយើងដឹងតែពីធ្វើការតាមកង។

**ស៖** អម្បាញ់មិញលោកស្រីបានលើកឡើងថា មានមេកងហ្នឹងបានចាប់ទៅដីកកប់ អាហ្នឹងពាក់ព័ន្ធនឹងរឿងគេធ្វើទារុណកម្មដោយមូលហេតុអ្វីដែរបាទ?

**ឆ៖** ចាស ពេលដែលខ្ញុំបាននិយាយថា ពេលគេចាប់ខ្ញុំទៅជីកកប់ហ្នឹង ពេលនោះ ខ្ញុំរត់គេចពីកងហ្នឹង ខ្ញុំសុំមិនបាន ខ្ញុំរត់គេចមក ដើម្បីរកជួបឪពុកម្តាយខ្ញុំ។

**ស៖** ហើយនៅតើពេលដែលគេកប់ហ្នឹង តើគេកប់នៅក្នុងចំណោមការប្រជុំហ្នឹង ឬមួយគេកប់តែម្នាក់ឯង ឬមួយគេជីកយ៉ាងម៉េច? ចង់ឲ្យជម្រាបអង្គជំនុំជម្រះមើលថា តើគេជីកកប់ហ្នឹង គេជីកកប់យ៉ាងម៉េច?

**ឆ៖** ចាស ពេលនោះ គេជីកដីកប់នោះ គេជីកជារណ្តៅមួយល្មមខ្លួនខ្ញុំហ្នឹង វាអត់ធំទេ វាតូចល្មម តែគេជីកខ្ញុំហ្នឹងកប់ខ្ញុំតែត្រឹមកទេ គេកប់ជាព្រមានខ្ញុំទេ ថាថ្ងៃក្រោយកុំឲ្យធ្វើអ៊ីចឹងទៀត។

**ស៖** ចុះតើពេលគេកប់ហ្នឹង គេមានឲ្យអាហារយើងហូបដែរអត់ទេ ពេលកប់ហ្នឹង?

[១៥:២១:០៦]

**ឆ៖** ចាស ពេលកប់ហ្នឹងអាហារអត់មានឲ្យខ្ញុំហូប ទឹកក៏ស្រេកចង់ស្លាប់ហើយ។ រីឯរាងកាយខ្ញុំហ្នឹងក៏ចុកចាប់ពេញខ្លួន ខ្ញុំស្រែកទ្រហោយំរកម៉ែរកឪមកជួយក៏មិនឃើញដែរ ព្រោះអីខ្ញុំកាលជីកកប់ហ្នឹង អត់មានជីកកប់ក្នុងអង្គប្រជុំឯណាទេ។ ជីកកប់ហ្នឹងពេលដែលគេយកខ្ញុំបានមកៗ អ៊ីចឹង ពេលកងកុមារខ្ញុំហ្នឹង ចេញទៅធ្វើការអស់ហើយ គេកប់ខ្ញុំហ្នឹងនៅកន្លែងកងហ្នឹងតែម្តង កងដែលស្នាក់អាស្រ័យនៅរាល់ថ្ងៃហ្នឹង។

**ស៖** សំណួរខ្ញុំចុងក្រោយ គឺខ្ញុំចង់ឲ្យលោកស្រីជម្រាបទៅអង្គជំនុំជម្រះវិញថា តើការបែកពីឪពុកម្តាយ ហើយអត់បានរៀនសូត្រហ្នឹងវាមានការឈឺចាប់ប៉ុនណា? ហើយអ្វីដែលលោកស្រីបានលើកឡើងអម្បាញ់មិញពាក់ព័ន្ធនឹងការគេចាប់កប់ក៏ដោយ ការគេចាប់វាយធ្វើបាបក៏ដោយ ចង់ឲ្យលោកស្រីលើកឡើងជាចុងក្រោយ ថាតើអាការៈឈឺចាប់ហ្នឹងវាប្រៀបផ្ទឹមទៅនឹងអ្វីបានដែរឬក៏អត់?

**ឆ៖** ការដែលជីកកប់ខ្ញុំហ្នឹង ខ្ញុំរកអ្វីប្រៀបផ្ទឹមពុំបានទេ ព្រោះអីខ្ញុំជាប់តែត្រឹមកហ្នឹង ទាំងអស់រលីង ហើយខ្ញុំមានដៃឯណារើបាន ខ្ញុំស្រែកទ្រហោយំហ្នឹង ខ្ញុំដឹងហៅម៉ែ ហៅឪឯណា បើរកម៉ែរកឪមិន

ឃើញ ឃើញតែការឈឺចាប់។

[១៥:២៣:០៨]

**ស៖** តើមកដល់ពេលនេះ ការឈឺចាប់របស់លោកស្រីត្រូវបានបាត់បង់ ហើយឬមួយនៅតែមានការរឭកទៅមានការឈឺចាប់បន្តទៀត ឬមួយយ៉ាងម៉េច បាទ?

**ឆ៖** ចាស មកដល់ពេលនេះ ការឈឺចាប់របស់ខ្ញុំ កាលណាខ្ញុំនឹកឃើញ ខ្ញុំនឹកឃើញនៅក្នុងមុខខ្ញុំជានិច្ច នឹកឃើញក្នុងខ្លួនក្នុងចិត្តខ្ញុំ ដូចកាលជំនាន់ដែលខ្ញុំរស់នៅ ដូចមុនហ្នឹងដដែលអ៊ីចឹង ឲ្យតែពេលខ្ញុំនឹកឃើញ។

**ស៖** ចំណុចមួយទៀត ចុះអ្វីដែលបន្សល់ទុកពីកាលនោះ ពីអ្វីដែលមិនបានចូលសាលារៀន ហើយមកដល់ឥឡូវហ្នឹង តើផលវិបាកហ្នឹងមកដល់លោកស្រីយ៉ាងម៉េចដែរ?

**ឆ៖** ចាស កាលពីជំនាន់នោះ ខ្ញុំអត់បានចូលសាលារៀន មិនបាននេះ បន្សល់ទុកដូចថា ឥឡូវហ្នឹងដល់ពេលនេះ ខ្ញុំដូចអត់មានការចេះដឹងអីហ្នឹងគេ អ៊ីចឹងបានត្រឹមត្រូវអីច្បាស់លាស់អី ព្រោះអីពេលនោះ ខ្ញុំអត់មានសាលារៀន អត់មានអីរៀនផង ដឹងតែធ្វើការ។

**ស៖** ចុះបញ្ហាសុខភាពវិញយ៉ាងម៉េចដែរ?

**ឆ៖** ចាស សុខភាពក៏មិនមាំមួនអីដែរ ព្រោះអីកាលនោះនៅក្មេងកុមារតូចប្រើធ្វើការហួសកម្លាំង។

[១៥:២៥:១៩]

**ស៖** ជាចុងក្រោយ តើលោកស្រីមានសំណួរអ្វីសម្រាប់ទៅជនជាប់ចោទទាំងពីរដែរឬទេ?

**ឆ៖** ចាស ខ្ញុំមានសំណួរចង់សួរពីរសំណួរដែរ។ សំណួរទី១ ខ្ញុំចង់សួរថា តើពួកលោកទាំងពីរហ្នឹងធ្វើទារុណកម្ម ធ្វើលើកុមារខ្ញុំអាយុជាតូចអ៊ីចឹង តើពួកគិត -- ពួកលោកគិតយ៉ាងម៉េចដែរនៅរបបនោះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី មានការអីទៅ?

**លោក គង់ សំអុន៖**

ខ្ញុំកត់សម្គាល់ឃើញថា ការលើកពីការតាំងសំណួរនេះហាក់ដូចជាមិនបានឆ្លងតាមរយៈលោកប្រធាន ដូច្នេះសូមឲ្យធ្វើតាមនីតិវិធីបែបនេះទៅបាទ សូមអរគុណ។

**លោក ឡោ ជុនធី៖**

បាទ សូមគោរពលោកប្រធាន ដោយសារសំណួរនេះ យើងបានស្នើសុំឲ្យខាងដើមបណ្ដឹងគាត់ធ្វើ ដូច្នេះគាត់អត់បានដឹងនីតិវិធីនេះ អ៊ីចឹងសូមឲ្យលោកប្រធានទទួលយកសំណួរនេះបាទ។

**ប្រធានអង្គជំនុំ៖**

អស់នៅ អស់សំណួរនៅ?

**លោក ឡោ ជុនធី៖**

ខ្ញុំបាទ អស់ហើយបាទ។

[១៥:២៧:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមជម្រាបជូនលោកស្រី អៀម យេន ថានៅក្នុងសវនាការកាលពីថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្ដាប់ជនជាប់ចោទទាំងពីររូបឆ្លើយបញ្ជាក់អំពីការដែលគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថា ជនជាប់ចោទទាំងពីររូបនៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែ និងរហូតដល់ពេលណាដែលជនជាប់ -- ដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្ដីឲ្យជនជាប់ចោទ។ នៅក្នុងសវនាការថ្ងៃនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និង/ឬ មេធាវីការពារក្ដីជនជាប់ចោទត្រូវមានការទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពប្រសិនបើជនជាប់ចោទ សម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបទៅនឹងសំណួរនៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការដែលសួរឡើងដោយអង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធ។ រហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្ដូរជំហររបស់ជនជាប់ចោទទាំងពីររូបនៅឡើយទេ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការយល់ព្រមឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះឬភាគីនោះ សូមជ្រាប។ ហើយក្រុមសហព្រះរាជអាជ្ញាតើមានសំណួរអី ទំនងជាមានសំណួរអីត្រូវសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដែរឬទេ?

[១៥:២៩:០៧]

**លោក ស្រ៊ា រតនៈ៖**

ជម្រាបឯកឧត្តម -- លោកប្រធានមាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណៗ។ សវនាការថ្ងៃនេះដល់ពេលត្រូវឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០២ ខែមេសា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយសវនាកានៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យេន និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូបទៀត គឺមានរហស្សនាម 2-TCCP-288, 2-TCCP-981 និង 2-TCCP-893។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។ ហើយអង្គជំនុំជម្រះសូមអរគុណលោកស្រី អៀម យេន ដំណើរការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មរបស់លោកស្រីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះអញ្ជើញលោកស្រីមកចូលរួមនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី អៀម យេន វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឱ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែក ឱ្យបានមុនម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រីបុគ្គលិកអង្គការ ធី.ភី.អូ ហើយអង្គជំនុំជម្រះក៏សូមអញ្ជើញលោកស្រីមកចូលរួមអង្គុយក្បែរ និងជួយពង្រឹងស្មារតីដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ នៅថ្ងៃស្អែកទៀតដែរ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញ នៅព្រឹកថ្ងៃស្អែក ឱ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៣១ នាទី)*